នៅចំពោះមុខការិយាល័យអង្គបុរេជំនុំជម្រះ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| |
|---|
| ឯកសារបកប្រែ |
| TRANSLATION/TRADUCTION |
| ថ្ងៃ ខែ ឆ្នាំ (Date): 05-Dec-2018, 08:00 |
| CMS/CFO: Sann Rada |

ព័ត៌មានលម្អិតអំពីការដាក់ឯកសារ

**សំណុំរឿងលេខ៖** ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-កសចស (អ.ប.ជ)

**ភាគីដាក់ឯកសារ៖** សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

**ដាក់ជូន៖** អង្គបុរេជំនុំជម្រះ (អ.ប.ជ)

**ភាសាដើម៖** អង់គ្លេស

**កាលបរិច្ឆេទនៃការដាក់ឯកសារ៖** ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយអង្គបុរេជំនុំជម្រះ៖** សម្ងាត់/Confidential

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖**

**ការពិនិត្យឡើងវិញចំពោះចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្ន៖**

**ឈ្មោះមន្ត្រីកត់ត្រា៖**

**ហត្ថលេខា៖**

---

# បណ្តឹងឧទ្ធរណ៍ជំទាស់នឹងការសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

---

| **ដាក់ដោយ៖** | | **ចំពោះមុខ៖** |
|---|---|---|
| **សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី** | | **អង្គបុរេជំនុំជម្រះ** |
| ជេត វណ្ណលី | Emmanuel JACOMY | ចៅក្រម ប្រាក់ គឹមសាន |
| ហុង គឹមសួន | Martine JACQUIN | ចៅក្រម Olivier BEAUVALLET |
| ឡោ ជុនធី | Daniel MCLAUGHLIN | ចៅក្រម ន័យ ថុល |

| | | |
|---|---|---|
| សំ សុគង់ | Lyma NGUYEN | ចៅក្រម BAIK Kang Jin |
| ស៊ិន សុវ៉ែន | Nushin SARKARATI | ចៅក្រម ហ្វួត វុទ្ធី |

ទី ស្រ៊ីនណា

វ៉េន ពៅ

**ចែកចាយជូន៖**

**សហចៅក្រមស៊ើបអង្កេត**
យូ ប៊ុនឡេង
Michael BOHLANDER

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារ អោ អាន**
មុំ លុដ្ឋ
Richard ROGERS
Göran SLUITER

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
Laure DESFORGES
Isabelle DURAND
គឹម ម៉េងឃី

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ បើកផ្លូវឲ្យធ្វើការស៊ើបអង្កេតតាមផ្លូវតុលាការប្រឆាំងនឹង អោ អាន អ៊ឹម ចែម និងយឹម ទិត្យ (សំណុំរឿង ០០៤)[1]។ ជាបន្តបន្ទាប់មកទៀត សហព្រះរាជអាជ្ញាអន្តរជាតិបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពង្រីកវិសាលភាពនៃការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤[2]។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេត (CIJs) បានចេញ*ដីកាបំបែកសំណុំរឿង ០០៤* ដោយផ្តាច់ អោ អាន ចេញពីសំណុំរឿង ០០៤ និងបង្កើតសំណុំរឿង ០០៤/២។ *សេចក្តីជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេតតាមផ្លូវតុលាការប្រឆាំង អោ អាន* ក៏ត្រូវបានចេញនៅពេលនោះផងដែរ[3]។

---

[1] សំណុំរឿងលេខ ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨។

[2] *សូមមើលជាអាទិ៍* សំណុំរឿងលេខ ០០៤ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ២៣។ សំណុំរឿងលេខ ០០៤ ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ១៤។ សំណុំរឿងលេខ ០០៤ ឯកសារ D254/1 ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវត្តតាមាក់ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥។ សំណុំរឿងលេខ ០០៤ ឯកសារ D272/1 ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃការស៊ើបអង្កេតលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥។

[3] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩ ឯកសារ D334 សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។ សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩ ឯកសារ D334/1 ដីកាបំបែក អោ អាន ពីសំណុំរឿង ០០៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។

2. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដោយឡែកពីគ្នាក្នុងសំណុំរឿង ០០៤/២[4]។ នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតជាតិ យល់ឃើញថា "អោ អាន មិនស្ថិតក្រោមយុត្តាធិការជាអ្នកដឹកនាំជាន់ខ្ពស់ ឬអ្នកទទួលខុសត្រូវបំផុតឡើយ] ហើយបានទម្លាក់បទចោទប្រឆាំង អោ អាន"[5]។ ដោយបានទម្លាក់រាល់បទចោទប្រឆាំង អោ អាន ដោយសារការខ្វះខាតយុត្តាធិការ សហចៅក្រមស៊ើបអង្កេតជាតិ មិនពិនិត្យលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ ទេ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពិតជាមានយុត្តាធិការលើ អោ អាន[6] ហើយបានចេញសេចក្តីសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដីកាដំណោះស្រាយដោយឡែកដែលក្នុងនោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននៅក្នុងសំណុំរឿង ០០៤/២ (ដីកាដែលរងការជំទាស់)[7]។ ការបកប្រែភាសាអង់គ្លេសនៃដីកាដំណោះស្រាយរបស់សហចៅក្រមអង្កេតជាតិ ត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី

[4] សំណុំរឿងលេខ ០០៤/២ ឯកសារ D360 ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនទៅជំនុំជម្រះ (កោសលុប) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។ សំណុំរឿង ០០៤/២ ឯកសារ D359 ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[5] សំណុំរឿងលេខ ០០៤/២ ឯកសារ D359 ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៨

[6] *សូមមើលជាទូទៅ* ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

[7] សំណុំរឿងលេខ ០០៤/២ ឯកសារ D362 ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ [តទៅនេះហៅថា "ដីកាដែលរងការជំទាស់"]។

២ ខែវិច្ឆិកា ឆ្នាំ២០១៨ ចំណែកអត្ថបទបកប្រែជាភាសាខ្មែរនៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨។

3. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលពាក្យសុំរបស់ពួកគេ ត្រូវបានបដិសេធនៅក្នុងដីកាដែលរងការជំទាស់ (ម្ចាស់បណ្តឹងឧទ្ធរណ៍) ត្រូវបានបង្ហាញអត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ក។

## II. ស្តង់ដារនៃបណ្តឹងឧទ្ធរណ៍

4. វិធាន៧៧ *ស្ទួន* ចែងអំពីការពន្លឿនដំណើរការប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចលើភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី។ យោងតាមវិធាន៧៧ *ស្ទួន* "ក្នុងរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងនៃសេចក្តីសម្រេចអំពីភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវដាក់បណ្តឹងឧទ្ធរណ៍នេះដោយមានបញ្ជាក់អំពីមូលហេតុដែលថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំលើអង្គហេតុ និង/ឬ អង្គច្បាប់ក្នុងការសម្រេចអំពីភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ដោយអនុលោមតាមវិធាន២៣ *ស្ទួន*"។

5. ចំពោះបណ្តឹងឧទ្ធរណ៍ "កំហុសលើអង្គច្បាប់ដែលបានលើកឡើង ត្រូវបានពិនិត្យ *ជាថ្មីឡើងវិញ* ដើម្បីពិចារណាថា តើសេចក្តីសម្រេចផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬអត់ ហើយកំហុសលើអង្គហេតុត្រូវបានពិនិត្យឡើងវិញស្របតាមបទដ្ឋានស្តីពីភាពសមស្រប ដើម្បីសម្រេចថា តើអ្នក

វិនិច្ឆ័យសេចក្តីទៅលើអង្គហេតុមិនប្រកបដោយហេតុផលដែលអាចនាំឲ្យឈានដល់ការសម្រេចទៅលើអង្គហេតុ ដែលបានលើកឡើងនេះដែរឬអត់”[8]។

III. **ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍**

6. ភាគីនៃសំណុំរឿង ០០៤/២ ត្រូវបានជូនដំណឹងអំពីដីកាដែលរងការជំទាស់នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/២ បានដាក់សំណើជារួម ស្នើសុំការពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនស្របតាមវិធាន៧៧ *ស្ទួន* នៃវិធានផ្ទៃក្នុង និងសុំការអនុញ្ញាតដាក់ពាក្យបណ្តឹងជាភាសាតែមួយ[9]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សំណើបន្ថែមមួយទៀត គាំទ្រលើសំណើរួមរបស់ខ្លួន នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨[10]។ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះ (អ.ប.ជ) បានអនុញ្ញាតតាមសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ដោយបានពន្យារពេលកំណត់សម្រាប់ការទទួលបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងភាពមិនអាចទទួលយកបាននៃអ្នក

---

[8] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៥។

[9] សំណុំរឿង ០០៤/២ ឯកសារ D362/1 សំណើជាបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រក្នុងការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨។

[10] សំណុំរឿង ០០៤/២ ឯកសារ D362/2 សារណាចូលរួម និងផ្តល់ការគាំទ្របន្ថែមទៅលើ “សំណើបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤/២” ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨។

ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/២ រយៈពេល៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជាភាសាខ្មែរ និងបន្ថែមចំនួនទំព័រនៃបណ្តឹងឧទ្ធរណ៍ ដល់៤៥ ទំព័រជាភាសាអង់គ្លេស ឬស្មើនឹង ៩០ ទំព័រជាភាសាខ្មែរ និងអនុញ្ញាតឲ្យដាក់ពាក្យបណ្តឹងជាភាសាតែមួយ[11]។ បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ជូនជាភាសាអង់គ្លេស និងភាសាខ្មែរ។ សំណៅបកប្រែឧបសម្ព័ន្ធជាភាសាខ្មែរ ឬអង់គ្លេស សមស្រប នឹងត្រូវដាក់ជូននៅពេលដែលការបកប្រែរួចរាល់។

7. បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ជូនទាន់ពេលវេលាក្នុងរយៈពេល៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ជាភាសាខ្មែររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្របតាមការកម្រិតចំនួន៤៥ ទំព័រជាភាសាអង់គ្លេស និង៩០ ទំព័រជាភាសាខ្មែរ ដែលត្រូវបានអនុញ្ញាតដោយអង្គបុរេជំនុំជម្រះ។

## IV. សំណើបឋម

8. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមធ្វើសំណើបឋមពីរខាងក្រោម។

9. សំណើទីមួយ ដូចបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ វិធាន ២៣ *ស្ទួន* នៃវិធានផ្ទៃក្នុង មានកម្មវត្ថុ និងគោលបំណងកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វិធាននេះមិនមានបំណងដាក់កំហិត ឬកម្រិតលើទស្សនៈនៃបណ្តឹងរបស់

[11] សំណុំរឿង ០០៤/២ ឯកសារ D362/4 សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យាររយៈពេលកំណត់ និងចំនួនទំព័រ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨។

ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ[12]។ វិធាន ២៣ *ស្ទួន*នៃវិធានផ្ទៃក្នុង ត្រូវតែបកស្រាយឲ្យស្របតាមវិធាន២១ ដែលកំណត់គោលការណ៍ជាមូលដ្ឋានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលក្នុងនោះឯកសារស្ថាបនារបស់អ.វ.ត.ក ត្រូវតែបកស្រាយ ដើម្បីការពារផលប្រយោជន៍របស់ជនរងគ្រោះជានិច្ច និងធានាថា សិទ្ធិរបស់ពួកគេត្រូវបានគោរពនៅក្នុងដំណើរការនីតិវិធីទាំងមូល[13]។ ដោយគោលការណ៍ជាមូលដ្ឋានសម្រាប់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺការផ្សះផ្សាជាតិ អង្គបុរេជំនុំជម្រះអះអាងថា គោលការណ៍នេះត្រូវតែណែនាំចៅក្រមអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថា "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនត្រឹមតែស្វែងរកការពិតអំពីអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏យកចិត្តទុកដាក់ជាពិសេស និងធានានូវការចូលរួមប្រកបដោយអត្ថន័យសម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត ដែលជាផ្នែកមួយនៃកិច្ចប្រឹងប្រែងរបស់ខ្លួន ក្នុងការស្វែងរកការផ្សះផ្សាជាតិ"[14]។ អាស្រ័យហេតុនេះ សិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ ដែលត្រូវបានតម្កល់នៅក្នុងឯកសារស្ថាបនា

---

[12] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦២។

[13] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦១។

[14] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៥។

របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពោលគឺនៅក្នុងវិធាន ២១ និងវិធាន ២៣ *ស្ទួន* ត្រូវតែចង្អុលបង្ហាញដល់អង្គបុរេជំនុំជម្រះនៅក្នុងការពិនិត្យដីកាដែលរងការជំទាស់ និងបណ្ដឹងឧទ្ធរណ៍នេះ។

10. សំណើទីពីរ អង្គបុរេជំនុំជម្រះគួរបញ្ជាក់អំពីឋានៈរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីគ្រប់រូបនៅក្នុងសំណុំរឿង ០០៤/២ ដោយសារសហចៅក្រមស៊ើបអង្កេតមិនយល់ស្របលើយុត្តាធិការ និងមិនយកចិត្តទុកដាក់ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។

11. ដីកាដែលរងការជំទាស់កំណត់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាពីរប្រភេទ៖ ១) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលពាក្យសុំរបស់ខ្លួនត្រូវបានទទួលយកដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងមិនត្រូវបានពិនិត្យដោយសហចៅក្រមស៊ើបអង្កេតជាតិ[15] និង ២) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលពាក្យសុំរបស់ខ្លួន ត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងមិនត្រូវបានពិនិត្យដោយសហចៅក្រមស៊ើបអង្កេតជាតិ[16]។ ដោយសារសហចៅក្រមស៊ើបអង្កេតជាតិ បដិសេធមិនពិនិត្យពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីណាមួយនោះ ពុំមានការព្រមព្រៀងធំដុំរវាងសហចៅក្រមស៊ើបអង្កេតចំពោះមូល

---

[15] សំណុំរឿង ០០២ ឯកសារ D362.1 ឧបសម្ព័ន្ធ ក៖ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៨។

[16] សំណុំរឿង ០០២ ឯកសារ D362.2 ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលស្គាល់ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៨។

ដ្ឋានសម្រាប់ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/២ ឡើយ។

12. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី រំលឹកឡើងវិញថា អនុលោមតាមវិធាន២៣ *ស្ទួន*(២) ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទទួលបានអត្ថប្រយោជន៍ពីការសន្មតទុកជាមុនពីភាពអាចទទួលយកបាន "លើកលែង និងលុះត្រា" ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះបដិសេធចោលដោយសហចៅក្រមស៊ើបអង្កេត[17]។ បើនិយាយឲ្យទូលំទូលាយជាងនេះ ការពិចារណាលើបញ្ហារបស់ដើមបណ្តឹងរដ្ឋប្បវេណី រាប់បញ្ចូលទាំងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែធ្វើការបកស្រាយឲ្យស្របតាមកម្មវត្ថុ បរិបទ និងគោលបំណងរបស់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលតម្រូវឲ្យតុលាការនេះ "យកចិត្តទុកដាក់ជាពិសេស និងធានានូវការចូលរួមប្រកបដោយអត្ថន័យសម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែង ក្នុងការស្វែងរកការផ្សះផ្សាជាតិ"[18]។

[17] វិធាន២៣ ស្ទួន(២) នៃវិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៩) ("[...]។ សហចៅក្រមស៊ើបអង្កេតអាចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់កាលបរិច្ឆេទចេញដីកាដំណោះស្រាយ។ ដីកានេះត្រូវបើផ្លូវឲ្យឧទ្ធរណ៍សង្ខេបទៅអង្គបុរេជំនុំជម្រះ ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងសេចក្តីណែនាំអនុវត្ត។ បណ្តឹងឧទ្ធរណ៍សង្ខេបនេះមិនផ្អាកដំណើរការនីតិវិធីទេ។ លើកលែង និងលុះត្រាតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធចោល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីបាន")។

[18] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៥។

ដូច្នេះ ភាពមិនច្បាស់លាស់ណាមួយពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គួរត្រូវបានដោះស្រាយ ដើម្បីជាប្រយោជន៍ដល់ការទទួលយក។

13. អង្គបុរេជំនុំជម្រះគួរអះអាងថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ ត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ដោយពិចារណាលើការសន្មតជាមុនពីភាពអាចទទួលយកបាន និងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការទទួលយកពួកគេជាដើមបណ្តឹងរដ្ឋប្បវេណី។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើថា ការសន្មតទុកជាមុនពីភាពអាចទទួលយកបាននេះបន្តអនុវត្តសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីគ្រប់រូប "លើកលែង និងលុះត្រាតែ" មានសេចក្តីសម្រេចមតិភាពច្រើនលើសលប់ ដែលមានសម្អាងហេតុផ្ទុយពីនេះរបស់អង្គបុរេជំនុំជម្រះ។

14. ស្រដៀងគ្នានេះដែរ អង្គបុរេជំនុំជម្រះសម្រេចថា ការសន្មតទុកជាមុនពីភាពអាចទទួលយកបានសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបដិសេធចោលដោយសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតតែមួយឡើយ។ ជាលទ្ធផល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ ដែលពាក្យសុំរបស់ខ្លួនត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងមិនត្រូវបានពិនិត្យដោយសហចៅក្រមជាតិ គួរតែអាចបន្តអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណី "លើកលែង និងលុះត្រាតែ" មានសេចក្តីសម្រេចមតិភាពច្រើនលើសលប់ ដែលមានសម្អាងហេតុផ្ទុយពីនេះរបស់អង្គបុរេជំនុំជម្រះ។

15. ផ្ទុយទៅវិញ បើសិនជាអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អាចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាឯកតោភាគីបាន សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមលើកឡើងថា ដីកាដែលរងការជំទាស់មានកំហុសលើអង្គហេតុ និងអង្គច្បាប់ ដូចបានបង្ហាញនៅក្នុងនៅក្នុងសារណាចម្លងខាងក្រោម។

## V. **សារណាចម្លង**

16. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសយ៉ាងច្បាស់លាស់លើអង្គហេតុ និងអង្គច្បាប់ ក្នុងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍។ ទីមួយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយមិនអាចអនុញ្ញាតបាន បានបន្ថយវិសាលភាពនៃឧក្រិដ្ឋកម្មដែលកំណត់ពីភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី មកនូវត្រឹមតែឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថាត្រូវបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) តែមួយប៉ុណ្ណោះ។ ធ្វើដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានគោរពការចោទប្រកាន់ថា អោ អាន បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម (JCE) និងបកស្រាយខុសពីការសន្មតទុកជាមុននៃព្យសនកម្មរួមដែលមានវិសាលភាពគ្របដណ្តប់សមាជិកគ្រប់រូបនៃក្រុម ឬសហគមន៍ដែលត្រូវបានគេកំណត់ជាគោលដៅដោយមិគិតពីទីកន្លែងរបស់ពួកគេឡើយ។ ទីពីរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ច្រឡំថា ដីកាបំបែកសំណុំរឿង ០០៤/២ គឺជាការដាក់កម្រិតបន្ថែមលើសមត្ថភាពរបស់ខ្លួន ក្នុងពិចារណាលើឧក្រិដ្ឋកម្មដែលត្រូវបានចោទថាបានប្រព្រឹត្តនៅក្រៅភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ដោយបង្កឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់ម្ចាស់បណ្តឹងរដ្ឋប្បវេណី។ ដូចបានពន្យល់ពិស្តារនៅក្នុង

មូលដ្ឋានទី៣ និងទី៤ នៃបណ្តឹងឧទ្ធរណ៍នេះ ដីកាដែលរងការជំទាស់ ក៏ខកខានមិនបានផ្តល់នូវសេចក្តីសម្រេចដែលមានសម្អាងហេតុសម្រាប់ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងមានកំហុសក្នុងការបដិសេធអ្នកដាក់ពាក្យសុំ ដោយសារការខកខានមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ និងមូលដ្ឋានដែលពាក់ព័ន្ធ។ ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតបានរំលោភសិទ្ធិរបស់ជនរងគ្រោះយ៉ាងទូលំទូលាយថែមទៀត តាមរយៈការខកខានក្នុងការផ្តល់ដំណឹងសមស្រប និងទាន់ពេលវេលាដល់ពួកគេអំពីដំណើរការនីតិវិធីទាំងមូល។

**ក. មូលដ្ឋានទី១នៃបណ្តឹងឧទ្ធរណ៍៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសលើអង្គច្បាប់ និងអង្គហេតុ ដោយគ្រាន់តែកំណត់អត្តសញ្ញាណឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ថាជាឧក្រិដ្ឋកម្មដែលពាក់ព័ន្ធទៅនឹងការតម្រូវដែលជាប់ទាក់ទងគ្នានៅក្រោមវិធាន២៣ *ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង។**

17. ដើម្បីចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី វិធាន២៣ *ស្ទួន*(១)(ខ) តម្រូវឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញថា "ខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត" "ជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើនដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ"។ កិច្ចស៊ើបសួររបស់សហចៅក្រមអន្តរជាតិលើភាពអាចទទួលយកបាន ពិនិត្យតែលើបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់ថាបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ប៉ុណ្ណោះ ដូច្នេះការស៊ើបអង្កេតនេះមានកំហុសធំៗពីរ៖ (ក) កិច្ចស៊ើបសួរនេះច្រានចោលការចូលរួមដែលត្រូវបានចោទប្រកាន់របស់ អោ អាន ក្នុងសហឧក្រិដ្ឋកម្មរួមទូទាំងប្រទេស (JCE) ដែលមានវិសាលភាពលាតសន្ធឹងក្រៅពីភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) និង(ខ) កិច្ចស៊ើបសួរនេះខកខានក្នុងការពិចារណាបានសមស្របលើការសន្មតទុកជាមុនពីព្យសន

កម្មសម្ងហភាព ដែលមានវិសាលភាពគ្របដណ្តប់លើក្រុម ឬសហគមន៍ដែលត្រូវបានគេកំណត់ជាគោលដៅតែមួយ ដោយមិនគិតពីទីកន្លែងរបស់ពួកគេ។

**ក. អោ អាន ត្រូវបានចោទប្រកាន់ថា បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ដែលមានគោលបំណងអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទូទាំងប្រទេស រាប់បញ្ចូលទាំងការអនុវត្តគោលនយោបាយទាំងនេះតាមរយៈឧក្រិដ្ឋកម្មនានានៅក្រៅភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់)**

18. ដីកាដែលរងការជំទាស់ច្រានចោលការសម្រេចមុនៗរបស់អង្គបុរេជំនុំជម្រះអំពីភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្តោតលើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) តែមួយប៉ុណ្ណោះ ទោះបីជាមានការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមថា អោ អាន បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដែលមានវិសាលភាពគ្របដណ្តប់ទូទាំងប្រទេសយ៉ាងណាក្តី។ វិធាន២៣ *ស្ទួន*(១)(ខ) កំណត់ច្បាស់ ហើយអង្គបុរេជំនុំជម្រះបានបញ្ជាក់ច្បាស់ថា ទំនាក់ទំនងដែលមិនអាចកាត់ផ្តាច់បាន មិនមែនជាទំនាក់ទំនងរវាងព្យសនកម្ម និងអង្គហេតុដែលត្រូវបានស៊ើបអង្កេតដោយសហចៅក្រមស៊ើបអង្កេតឡើយ គឺវាតម្រូវឲ្យមានទំនាក់ទំនងរវាងព្យសនកម្ម និង*ឧក្រិដ្ឋកម្មណាមួយដែលត្រូវបានចោទប្រកាន់តែប៉ុណ្ណោះ*[19]។ ការញែកដាច់ពីគ្នាដ៏សំខាន់នេះ គឺជាការបែងចែកនៃអង្គច្បាប់ និងអង្គហេតុ ដោយឧក្រិដ្ឋកម្ម គឺជា "ការកំណត់ប្រភេទបទល្មើសដែលត្រូវបានស៊ើបអង្កេត"[20]។

[19] វិធានផ្ទៃក្នុង២៣ ស្ទួន(១)(ខ) (បន្ថែមពាក្យសង្កត់ន័យ)។

[20] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១

19. នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះបានធ្វើការសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតបានបដិសេធមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយមិនសមស្រប ដោយដាក់លក្ខខណ្ឌមិនត្រឹមត្រូវ ដែលតម្រូវឱ្យអ្នកដាក់ពាក្យសុំផ្សាភ្ជាប់ទំនាក់ទំនងព្យសនកម្មរបស់ខ្លួនជាមួយស្ថានភាពអង្គហេតុដែលស៊ើបអង្កេតដូចបានបង្ហាញនៅក្នុងដីកាដំណោះស្រាយ[21]។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា "ទោះបីជាអង្គហេតុដែលត្រូវស៊ើបអង្កេតកំណត់ត្រឹមតែទៅលើតំបន់ ឬទីតាំងឧក្រិដ្ឋកម្មមួយចំនួនក៏ដោយ ក៏ការកំណត់បទចោទនៃអង្គហេតុ [...] បានរួមបញ្ចូលនូវឧក្រិដ្ឋកម្ម ដែលតំណាងឱ្យអំពើឃោរឃៅជាទ្រង់ទ្រាយធំ [...] ក្នុងពេលអនុវត្តសហឧក្រិដ្ឋកម្មរួម [...] *ប្រឆាំងប្រជាជន* **និង** *"នៅទូទាំងប្រទេស"*[22]។ អង្គបុរេជំនុំជម្រះបានកំណត់ថា "វាគឺជាការកំណត់បទចោទទៅលើស្ថានភាពអង្គហេតុដែលត្រូវធ្វើការស៊ើបអង្កេត [*ពោលគឺ*បទឧក្រិដ្ឋដែល

---

កថាខណ្ឌ ៤២។ *សូមមើលផងដែរ រដ្ឋអាជ្ញាតទល់នឹង Ayyash និងអ្នកដទៃទៀត* STL-11-01/PT/PTJ, F0879, សេចក្តីសម្រេចលើកទី៤ ស្តីពីការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការនីតិវិធី ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌ ១៥ (សម្រេចថា ទំនាក់ទំនងហេតុ និងផលស្ថិតនៅរវាងព្យសនកម្មដែលបានអះអាង និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ជាក់លាក់នៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះ" និងពន្យល់ថា "ការបកស្រាយនេះផ្តល់ចរិតលក្ខណៈផ្លូវច្បាប់ដល់ប៉ារ៉ាម៉ែត្រនៃធាតុផ្សំហេតុផលដែលតាមរយៈនេះផ្តល់នូវសច្ចភាព និងភាពមិនលម្អៀងកាន់តែច្រើន" ដល់ដំណើរការចូលរួមរបស់ជនរងគ្រោះ)។

[21] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤២។

[22] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤២ (សេចក្តីដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

ត្រូវបានចោទប្រកាន់] មិនមែនជាស្ថានភាពអង្គហេតុដែលត្រូវធ្វើការស៊ើបអង្កេតនោះទេ ដែលសហចៅក្រមស៊ើបអង្កេតគួរធ្វើការពិចារណា[.]"[23]។

20. ក្នុងករណីដែលដីកាដំណោះស្រាយកំណត់ថា ការវាយប្រហារទៅលើជនស៊ីវិលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី "មិនចាំបាច់ត្រូវបង្ហាញពីទំនាក់ទំនងរវាងព្យសនកម្មរបស់ខ្លួនទៅនឹងទីតាំងឧក្រិដ្ឋកម្មតែមួយ ឬទីតាំងឧក្រិដ្ឋកម្មនានាដែលមានរៀបរាប់" នៅក្នុងដីកាដំណោះស្រាយទេ ជាពិសេសនៅពេលដែល "បទឧក្រិដ្ឋទាំងនោះ និងគោលនយោបាយជាមូលដ្ឋានរបស់ខ្មែរក្រហមបង្កើតជាមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានអនុវត្តនៅទូទាំងប្រទេសកម្ពុជា"[24]។ អ្វីដែលគួរឲ្យកត់សម្គាល់ អង្គបុរេជំនុំជម្រះបានសង្កត់ធ្ងន់ថា "ការទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងទិដ្ឋភាពនៃអំពើឃោរឃៅជាទ្រង់ទ្រាយធំគួរតែ [...] សំដៅដល់បរិបទដែលឆ្លើយតបទៅនឹងសកម្មភាពដែលបានប្រព្រឹត្តយ៉ាងទូលំទូលាយ [*ស៊ីក*] និងជាប្រព័ន្ធ ដែលកើតចេញពីការអនុវត្តនូវគោលនយោបាយទាំងនេះនៅទូទាំងប្រទេស ដែលក្នុងនោះការទទួលខុសត្រូវជាលក្ខណៈបុគ្គលដែលបានចោទប្រកាន់លើជនជាប់ចោទម្នាក់ៗ គួរធ្វើជា

---

[23] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤២។

[24] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧២ (ពាក្យសង្កត់ន័យខាងក្នុងត្រូវបានលុបចោល)។

លក្ខណៈរួមវិញ ដោយសារមានការចោទប្រកាន់ពីការធ្វើសកម្មភាពរួមគ្នាជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម"[25]។

21. គោលជំហររបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ អនុវត្តដោយមានទម្ងន់ស្មើគ្នាត្រង់ចំណុចនេះនៅក្នុងសំណុំរឿង ០០៤/២។ យោងតាមដីកាដំណោះស្រាយ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម អោ អាន បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ដែលមានគោលដៅអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅទូទាំងប្រទេស ពោលគឺមិនមែននៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) តែមួយឡើយ[26]។

[25] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧៨។ អ្វីដែលគួរឱ្យកត់សម្គាល់គឺថា ជនជាប់ចោទអាចត្រូវបានតម្រូវឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម "ទោះបីជាការរួមចំណែកជាដុំកំភួនរបស់គាត់ចំពោះសហឧក្រិដ្ឋកម្មនោះ បានធ្វើឡើងនៅក្នុងតំបន់ភូមិសាស្ត្រដ៏តូចតាចក៏ដោយ" ឱ្យតែគាត់បានដឹងអំពីគោលបំណងទូលំទូលាយនៃផែនការរួមនោះ"។ សាលក្រមក្នុងរឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Sesay, Kallon and Gbao*, SCSL-04-15-T ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ២៦២។

[26] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៨២៤ ("អោ អាន និងកម្មាភិបាលដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា មានគោលបំណងរួមក្នុងការអនុវត្តគោលនយោបាយចំនួនបួនរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងភូមិភាគកណ្តាលរបស់កម្ពុជាប្រជាធិបតេយ្យ"។ *សូមមើលផងដែរ ឯកសារខាងលើ* កថាខណ្ឌ ១៩៥-១៩៧, ២១០, ២១១, ២១៨, ២២០ (ដែលកត់សម្គាល់ពីតួនាទីរបស់ អោ អាន ក្នុងការអនុវត្តគោលនយោបាយជាតិទាំងបួនរបស់បក្សកុម្មុយនីស្តកម្ពុជា៖ ១) បង្កើតសហករណ៍ និងការដ្ឋាន "ទូទាំងកម្ពុជាទាំងមូល", ២) ចាប់ខ្លួន និងសម្លាប់ខ្មាំងតាមរយៈបណ្តាញមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ទូទាំងប្រទេស" ដែលមានការចូលរួមពីរដ្ឋបាលស៊ីវិល និងកងទ័ពបដិវត្តកម្ពុជាគ្រប់កម្រិត", ៣) បោសសម្អាតកម្មាភិបាល "ក្បត់" នៅភូមិភាគកណ្តាល និងភូមិភាគបូព៌ា និង៤) "ការដាក់បទបញ្ជាលើ" អាពាហ៍ពិពាហ៍ទូទាំងប្រទេស")។ សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ១១១។ *សូមមើលផងដែរ* កថាខណ្ឌ ១៦, ១០៩។ សំណុំរឿង ០០៤ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ កថខណ្ឌ ២១។ សំណុំរឿង ០០៤ ឯក

បក្សកុម្មុយនីស្តកម្ពុជារក្សាបាននូវប្រព័ន្ធមួយដែលមានអង្គការចាត់តាំងត្រឹមត្រូវសម្រាប់ការអនុវត្ត គោលនយោបាយជាតិរបស់ខ្លួន តាមរយៈបណ្តាញអង្គការចាត់តាំងថ្នាក់ភូមិភាគ ដែលរួមមានអង្គការចាត់តាំងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) របស់ អោ អាន។ ដូចបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ "ការចាប់ខ្លួន និងការបាត់ខ្លួននៅទូទាំងភូមិភាគកណ្តាល ដែលគេបានឃើញកើតមានក្រោយការចូលមកដល់របស់ [អោ អាន] និងកម្មាភិបាលភាគនិរតី [...] កំណត់ថា នោះគឺជាការខិតខំប្រឹងប្រែងមានអង្គការចាត់តាំងដែលរៀបចំផែនការដោយ [អោ អាន] និង*អ្នកដឹកនាំដទៃទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា* [ក៏ប៉ុន្តែ] ត្រូវបានអនុវត្តដោយ [អោ អាន] និងកម្មាភិបាលរបស់គាត់មកពីភូមិភាគនិរតី"[27]។ ដីកាដំណោះស្រាយចោទប្រកាន់ថា អោ អាន បានទទួលការណែនាំពីប៉ុល ពត ផ្ទាល់ ដោយគូសបញ្ជាក់ថា ការចូលរួមរបស់ អោ អាន ក្នុងសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ត្រូវបានដឹង និងជួយសម្របសម្រួលដោយថ្នាក់ដឹកនាំកម្រិតខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា[28]។ ប្រតិបត្តិការទាំងមូលត្រូវរៀបចំឡើង ដើម្បីពង្រឹង*គោលដៅថ្នាក់ជាតិ*នៃការ

សារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ១៤។

[27] សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៩០(ខ) (បន្ថែមពាក្យសង្កត់ន័យ)។

[28] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៨២៥ (ចោទប្រកាន់ថា "អោ អាន បានក្លាយជាសមាជិកម្នាក់នៃសហឧក្រិដ្ឋកម្មរួមនេះមិនហួសពីពេលដែលគាត់បានចូលរួមប្រជុំមួយនៅភ្នំពេញ ជាមួយនឹងមេដឹកនាំថ្នាក់ខ្ពស់ទាំងឡាយនៃបក្សកុម្មុយនីស្តកម្ពុជា ក្នុងដំណើររបស់គាត់ដែលចេញពីភូមិភាគនិរតី ឆ្លងទៅកាន់ភូមិភាគកណ្តាល នៅក្នុងចំណុចពេលណាមួយ ចន្លោះពីចុងឆ្នាំ១៩៧៦ ដល់ខែកុម្ភៈ ឆ្នាំ១៩៧៧ ដែលក្នុងអំឡុងពេលនោះគាត់ត្រូវបានប៉ុល ពត បញ្ជាឱ្យបោសសម្អាតភូមិភាគកណ្តាល ហើយគាត់បានបន្តកាន់នាទីជាសមាជិកម្នាក់រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩")។

បង្កើតរចនាសម្ព័ន្ធថ្មីរបស់សង្គមកម្ពុជាទាំងមូល[29]។ ប្រាកដណាស់ ភូមិភាគនិរតីត្រូវបានគេចាត់ទុកជា "គំរូសម្រាប់ការបង្កើតទម្រង់នៃសង្គមថ្មី" នៅកម្ពុជា ហើយការបោសសម្អាតនៅក្នុងភូមិភាគកណ្តាលដោយពួកកម្មាភិបាលភាគនិរតី បានកើតឡើងផ្តើមចេញពីការបរាជ័យរបស់កម្មាភិបាលចាស់ "ក្នុងការសម្រេចគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា"[30]។ ដីកាដំណោះស្រាយ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរៀបរាប់ និងពិភាក្សាពីមន្ទីរសន្តិសុខ គុក និងទីតាំងសម្លាប់មួយចំនួន ដែលបានធ្វើប្រតិបត្តិការនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ក្រោមការគ្រប់គ្រងរបស់ អោ អាន ជាផ្នែកមួយនៃគម្រោងថ្នាក់ជាតិដ៏ទូលំទូលាយ[31]។

22. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពណ៌នាពីរបៀបដែលការប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ត្រូវបានធ្វើឡើងក្នុងបំណងពន្លឿនការសម្រេចផែនការឧក្រិដ្ឋ

---

[29] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ១៩៦ (បក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ចង់ផ្លាស់ប្តូរប្រទេសកម្ពុជា ពីសេដ្ឋកិច្ចទីផ្សារ ទៅជារដ្ឋសង្គមនិយមខ្លួនទីពឹងខ្លួនផ្អែកលើសេដ្ឋកិច្ចកសិកម្ម)។ ឯកសារដដែលខាងលើ កថាខណ្ឌ ២០៨ ("គោលបំណងរបស់ ប.ក.ក [ក្នុងការលុបបំបាត់ "សមាសភាពអាក្រក់" និង "ខ្មាំង"] គឺដើម្បីបង្កើតបក្ស និងសង្គមស្អាតស្អំខាងនយោបាយ និងមនោគមន៍វិជ្ជា")។ ឯកសារដដែលខាងលើ កថាខណ្ឌ ២២៤ ("គោលនយោបាយ ប.ក.ក ស្តីពីការៀបអាពាហ៍ពិពាហ៍ ត្រូវបានរៀបចំឡើង ដើម្បីបង្កើនចំនួនប្រជាជន និងកសាងគ្រួសារ ដែលស្អាតស្អំខាងមនោគមន៍វិជ្ជា")។ សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៩, ១០។

[30] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ២១៣។ សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៩, ១០។

[31] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៣៥៦-៥៨៩។ សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ២៣-៥៣។

កម្មរួមនៅទូទាំងប្រទេស ដែលក្នុងនោះ អោ អាន ក្នុងចំណោមអ្នកដទៃទៀត ក៏បានចូលរួមចំណែកក្នុងការអនុវត្ត៖

> "បទឧក្រិដ្ឋដូចបានរៀបរាប់ ក្នុង [ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមស្តីពីខ្មែរក្រោម] និងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ត្រូវបានគេប្រព្រឹត្តឡើងក្នុងការជួយពន្លឿនបន្ថែមនៃផែនការឧក្រិដ្ឋកម្មរួម ឬ [សហឧក្រិដ្ឋកម្មរួម] របស់មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា [...] សមាជិករបស់សហឧក្រិដ្ឋកម្មរួមនេះរួមមាន ប៉ុន្តែមិនមានកំហិតត្រឹមតែប៉ុណ្ណឹងទេ សមាជិកនានារបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា មេដឹកនាំក្រសួង និងលេខាភូមិភាគ តំបន់ និងកងពលយោធានៃមជ្ឈិមបក្ស។ ផែនការឧក្រិដ្ឋកម្មរួមត្រូវបានគេអនុវត្តដោយបានដឹកជាមុនដោយមនុស្សជាច្រើន រួមមានលេខាស្រុករបស់បក្សកុម្មុយនីស្តកម្ពុជា និងប្រធានមន្ទីរសន្តិសុខ ដែលម្នាក់ៗក៏ជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមស្ថិតនៅក្នុងស្រុក ឬមន្ទីរសន្តិសុខរបស់ពួកខ្លួន។ បុគ្គលម្នាក់ៗទាំងនេះ តាមរយៈអំពើ និងការប្រព្រឹត្តរបស់ពួកគេ បានរួមចំណែកធ្វើឱ្យសម្រេចនូវគោលដៅរួមនៃសហឧក្រិដ្ឋកម្មរួម និងដែលមានចេតនាចង់បានលទ្ធផលទៅតាមនោះ"32។

ដូចគ្នាដែរ ដីកាដំណោះស្រាយគូសបញ្ជាក់ពីរបៀបដែលការប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងភូមិភាគកណ្តាល (ឧត្តរចាស់) និងការចូលរួមរបស់ អោ អាន នៅក្នុងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាំងនេះ ត្រូវបានធ្វើឡើង ដើម្បីធ្វើឱ្យសម្រេចនូវគោលដៅរួមនៃសហឧក្រិដ្ឋកម្មរួមទូទាំងប្រទេសរបស់បក្សកុម្មុយនីស្តកម្ពុជា។ ឧទាហរណ៍ នៅក្នុងបរិបទនៃការសម្លាប់ខ្មាំង អោ អាន ត្រូវបានចោទប្រកាន់ថាបានធ្វើ "ការប្រកាសជាច្រើនលើក បង្ហាញពីការប្តេជ្ញាចិត្តរបស់គាត់ក្នុងការអនុវត្តផែនការរបស់ "អង្គការ"[33]

---

[32] សំណុំរឿង ០០៤ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ២១។

[33] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៨២៨ ("អោ អាន និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដទៃទៀតមានគោលបំណងរួមក្នុងការអនុវត្តគោលនយោបាយទាំងបួនរបស់ ប.ក.ក នៅក្នុងភូមិភាគកណ្តាលរបស់កម្ពុជាប្រជាធិបតេយ្យ")។

។ ដីកាដំណោះស្រាយសម្រេចថា អោ អាន បានធ្វើ "ការចូលរួមចំណែកជាដុំកំភួន" ចំពោះគោលនយោបាយនីមួយៗនៃគោលនយោបាយជាតិទាំងបួនរបស់បក្សកុម្មុយនីស្តកម្ពុជា[34]។

23. ដីកាដំណោះស្រាយ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពោរពេញទៅដោយការចោទប្រកាន់ពីការចូលរួមរបស់ អោ អាន ក្នុងសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ដែលគ្របដណ្តប់លើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើសពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) តែមួយ រាប់បញ្ចូលទាំងតួនាទីដ៏សំខាន់របស់គាត់នៅក្នុងការបោសសម្អាតកម្មាភិបាល និងជនស៊ីវិលនៅភូមិភាគបូព៌ា[35]។ កម្មវត្ថុរបស់

[34] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៨២៧-៨២៩, ៨៣១។

[35] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៣០៧។ *សូមមើលផងដែរ* សំណុំរឿង ០០៤ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថខណ្ឌ ២៣ (បញ្ជាក់ថា សហព្រះរាជអាជ្ញាអន្តរជាតិ "មានមូលហេតុដែលនាំឱ្យជឿបាន" ថា អោ អាន និងអ្នកដទៃទៀតធ្វើប្រតិបត្តិការនៅក្រៅភូមិភាគកណ្តាល (ឧត្តរចាស់) រួមទាំង យឹម ទិត អ៊ឹម ចែម នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ "បានប្រព្រឹត្តអំពើឧក្រិដ្ឋជាក់លាក់ដូចបានរៀបរាប់" នៅក្នុងដីកាសន្និដ្ឋាននោះ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ជាផ្នែកនៃផែនការឧក្រិដ្ឋកម្មរួម ឬសហឧក្រិដ្ឋកម្មរួម [.])។ សំណុំរឿង ០០៤ ឯកសារ D254/1 ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវត្តតាមាក់ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ កថាខណ្ឌ ៨ (ដូចគ្នា)។ សំណុំរឿង ០០៤ ឯកសារ D272/1 ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ កថាខណ្ឌ ១៤ (ដូចគ្នា)។ សំណុំរឿង ០០៤ ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ១៤ (ចោទប្រកាន់ថា អំពើដែលបានរៀបរាប់ទាំងនេះ "គឺជាផ្នែកនៃផែនការឧក្រិដ្ឋកម្មរួម ឬសហឧក្រិដ្ឋកម្មរួម"។ *សូមមើលផងដែរ* សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ១៧

សហឧក្រិដ្ឋកម្មរួមនៅក្នុងភូមិភាគកណ្ដាល "គឺត្រូវបោសសម្អាតនៅភូមិភាគកណ្ដាល (ភូមិភាគឧត្តរចាស់) និងសម្លាប់រាល់ខ្មាំងរបស់*[បក្សកុម្មុយនីស្តកម្ពុជា] នៅក្នុងភូមិភាគនោះ*"[36]។ យោងតាមដីកាដំណោះស្រាយ ការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ានៅក្នុងភូមិភាគកណ្ដាល គឺមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ផែនការរួមរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយការបោសសម្អាតទាំងនេះត្រូវបានរាយការណ៍នៅក្នុងទស្សនាវដ្ដី "ទង់បដិវត្ត" របស់បក្ស[37]។ ក្រុមដែលត្រូវបានកំណត់ជាគោលដៅជាក់លាក់សម្រាប់ឧក្រិដ្ឋកម្មរួមនេះ គឺខ្មាំងនៅទូទាំងប្រទេស រាប់បញ្ចូលទាំង "ជនជាតិចាម អ្នកកាន់សាសនា និងអ្នកមានជាតិពន្ធុវៀតណាម"[38]។

24. លើសពីនេះទៀត ដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ អោ អាន មានតួនាទីខ្ពស់[39] នៅក្នុងការអនុវត្តគោលនយោបាយជាតិ ដោយបានបម្រើការងារជា "សមាជិកមានឋានៈខ្ពស់បំផុតលំដាប់ទីពីររបស់បក្សកុម្មុយនីស្តកម្ពុជានៅភូមិភាគ

---

(ចោទប្រកាន់ពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មថ្នាក់ភូមិភាគពាក់ព័ន្ធមួយទៀត ដែលរួមមានតាម៉ុក តាទិត អ៊ឹម ចែម និងអ្នកដទៃទៀតដែលមានលក្ខណៈស្ទើរតែដូចគ្នានឹងភូមិភាគកណ្ដាល ប៉ុន្តែមានកម្មវត្ថុបោសសម្អាតភូមិភាគពាយ័ព្យដែលនៅជិតខាង)។

[36] សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ១៦ (បន្ថែមពាក្យសង្កត់ន័យ)។

[37] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ២១៦ (យោង ឯកសារ D6.1.740 ទស្សនាវដ្ដីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើងថា៖ "ទង់បដិវត្តកម្ពុជា លេខពិសេស តុលា-វិច្ឆិកា ១៩៧៧)។

[38] សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ១៦។ *សូមមើលផងដែរ* សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ២១៨។

[39] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៧០០។

កណ្តាល" និង "ជាលេខាភូមិភាគ*តាមជាក់ស្តែង*[40]"។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏បញ្ជាក់ដែរថា អោ អាន ជា "សមាជិក "គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជានៅក្នុងមហាសន្និបាតបក្សលើកទី៥"[41] និងជាមេដឹកនាំម្នាក់ក្នុងចំណោម "មេដឹកនាំថ្នាក់តំបន់ ពីរបីនាក់...." ដែលរស់រានមានជីវិតពីសម័យកម្ពុជាប្រជាធិបតេយ្យ"[42]។

25. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម លើកឡើងថា ដោយសារតួនាទីជាមេដឹកនាំជាន់ខ្ពស់របស់គាត់ អោ អាន មានភារកិច្ចអនុវត្តគោលនយោបាយទូទាំងប្រទេស រាប់បញ្ចូលទាំង៖ ការធ្វើឲ្យប្រជាជនក្លាយទៅជាទាសករនៅតាមបណ្តាសហករណ៍ ឬការដ្ឋានពលកម្មដោយបង្ខំនានា ការកំណត់អត្តសញ្ញាណ និងលុបបំបាត់ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជាតាមរយៈខ្សែបណ្តាញនៃមន្ទីរសន្តិសុខ និងទីតាំងសម្លាប់នានា ការដាក់ចំណុចដៅទៅលើក្រុមសង្ស័យនានា ដូចជា ចាម និងវៀតណាម និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[43]។

---

[40] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ២៥០, ២៥៥, ៧០៥។ សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៨៦។

[41] សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៨៦។

[42] សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៨៩ (ការស្រង់សម្តីខាងក្នុងត្រូវបានលុបចោល)។

[43] សំណុំរឿង ០០៤ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថខណ្ឌ ២១។ សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ១៦។ សំណុំរឿង ០០៤ ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ១៣-១៤។ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យ

ដីកាដំណោះស្រាយលើកឡើងថា អោ អាន បានចូលរួមពាក់ព័ន្ធនៅក្នុងការអនុវត្តគោលនយោបាយជាតិទាំងបួន គឺការបង្កើតសហករណ៍ និងការដ្ឋាន និងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដើម្បីឲ្យពួកគេទៅធ្វើការនៅតាមទីតាំងទាំងនោះ" ការកសាង "សមាសភាពមិនល្អ" និងការសម្លាប់ខ្មាំងទាំងក្នុង និងក្រៅជួរ ប.ក.ក ការកំណត់គោលដៅលើក្រុមជាក់លាក់ និងការដាក់បទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[44]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ពន្យល់លម្អិតពីតួនាទីរបស់ អោ អាន នៅក្នុងផែនការឧក្រិដ្ឋកម្មរួម ឬសហឧក្រិដ្ឋកម្មរួម "ក្នុងការកំណត់ទិសដៅជាក់លាក់លើកម្មាភិបាលមូលដ្ឋាន ក្រុមគ្រួសារ និងខ្សែបណ្តាញរបស់អ្នកទាំងនោះ" ព្រមទាំងប្រជាជនដែលមានទំនាក់ទំនងជាមួយ "សង្គមចាស់" ប្រជាជនថ្មី ឬប្រជាជន១៩៧៥"[45]។ គោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ក៏រួមមានផងែរ "ការជម្លៀសប្រជាជនពីទីក្រុង"[46] និងការសម្លាប់ ក៏ដូចជាការធ្វើទុក្ខបុកម្នេញ "រាល់អ្នកដែលរបបគិតថាជាខ្មាំង ឬជនក្បត់ទាំងអស់នៅក្នុងចំណោមប្រជាជន ឬនៅក្នុងជួរកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា...[ជាពិសេស] "ប្រជាជនថ្មី" អ្នកដែលមានជាតិពន្ធុវៀតណាម និង ...ជនជាតិភាគតិចចាម"[47]។ ដីកាដំណោះស្រាយកំណត់

ស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃការស៊ើបអង្កេតលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១ និងតំបន់៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ កថាខ័ណ្ឌ ១៤។

[44] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ១៩៥-១៩៦។

[45] សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ១៦។

[46] សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៧។

[47] សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៧។

អត្តសញ្ញាណក្រុមស្រដៀងគ្នានេះជាច្រើន ដែលត្រូវបានកំណត់ជាគោលដៅដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា រួមមាន "ប្រជាជន ១៧ មេសា" "អ្នកជាប់ពាក់ព័ន្ធនឹងអតីតរបប លន់ នល់" "កម្មាភិបាល ប.ក.ក ដែលគេចោទថាធ្វើ "សកម្មភាពក្បត់" "អ្នកដែលត្រូវគេចោទថាជាគិញសេអ៊ីអា កាហ្សេបេ ឬវៀតណាម (យួន) ជនជាតិចាម និងអ្នកដែលត្រូវគេសន្មតថាជាវណ្ណៈ "នាយទុន" "សក្តិភូមិ" "ម្ចាស់ដី" ឬ "អនុធន" និងគ្រួសាររបស់អ្នកដែលត្រូវគេកំណត់ជាគោលដៅ[48]។ បក្សកុម្មុយនីស្តកម្ពុជាអនុវត្តគោលនយោបាយទាំងនេះតាមរយៈ "ខ្សែបណ្តាញមន្ទីរសន្តិសុខ*នៅទូទាំងប្រទេស*" "ការបោសសម្អាត" និងការសម្លាប់កម្មាភិបាល អ្នកដែលគេគិតថាជាខ្មាំង ឬជនក្បត់" និង "សមាសភាពមិនល្អ" ទាំងនៅក្នុង និងនៅក្រៅជួរបក្សកុម្មុយនីស្តកម្ពុជា[49]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ក៏ពន្យល់ពិស្តារផងដែរអំពីការចោទប្រកាន់ពីអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ និងអំពើរំលោភសេពសន្ថវៈ[50] ព្រមទាំងអំពើធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍លើខ្មែរក្រោម ជាឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយមេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា

---

[48] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ២១៨, (រាប់បញ្ចូលទាំងចំណុច ៦.២.៣)។

[49] សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពាររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៨, ១២ (បន្ថែមពាក្យសង្កត់ន័យ)។ សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ២០៤, ២០៨។

[50] សំណុំរឿង ០០៤ ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ១៣-១៤។

រួមទាំង អោ អាន ក្នុងការជួយពន្លឿនផែនការឧក្រិដ្ឋកម្មរួម ឬសហឧក្រិដ្ឋកម្មរួមនេះ ដែលត្រូវបានអនុវត្តនៅទូទាំងប្រទេស[51]។

26. ទោះបីជាមានការបង្ហាញយ៉ាងច្បាស់ប្រចក្សអំពី "លក្ខណៈជារួម" នៃការទទួលខុសត្រូវរបស់ អោ អាន ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្តោតជាពិសេសលើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) តែមួយប៉ុណ្ណោះ ក្នុងការកំណត់ពីភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី។ នេះគឺជាកំហុស។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គួរតែបានពិចារណាលើឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តនៅក្រៅភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ដែលក្នុងនោះឧក្រិដ្ឋកម្មទាំងនេះបង្កើតបានជាផ្នែកនៃសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិដែល អោ អាន ក៏ជាសមាជិកម្នាក់ដែរ មានភាពពាក់ព័ន្ធសម្រាប់ការវិភាគលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

27. ក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤/២ គឺជាជនរងគ្រោះដែលបានទទួលរងព្យសនកម្ម ដែល

---

[51] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ១៤។ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃការស៊ើបអង្កេតលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១ និងតំបន់៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ កថាខ័ណ្ឌ ១៤។ សំណុំរឿង ០០៤ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថខណ្ឌ ២១, ២៣។

ជាផលវិបាកនៃការអនុវត្តគោលនយោបាយទាំងបួន ដើម្បីពន្លឿនការសម្រេចផែនការឧក្រិដ្ឋកម្មរួមនៃសហឧក្រិដ្ឋកម្មរួម ដូចរៀបរាប់ខាងក្រោម។

(១) លោក ឈុំ ហុន ជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (13-VSS-00633) និងគ្រួសាររបស់គាត់ បានទទួលរងការឈឺចាប់ពីលក្ខខណ្ឌរស់នៅ និងការងារដ៏សែនលំបាកវេទនានៅក្នុងសហករណ៍មួយស្ថិតក្នុងខេត្តបាត់ដំបង។ ដោយសារគ្រួសារគាត់ជាប្រជាជនថ្មី គេបានជម្លៀសពួកគាត់ និងប្រជាជនថ្មីដទៃទៀតចេញពីទីរួមស្រុកកៀនស្វាយ ខេត្តកណ្តាល ឲ្យទៅរស់នៅភូមិត្រោះ ឃុំសែ ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ពេលទៅដល់ទីនោះ គេបានបញ្ជាឲ្យប្រជាជនថ្មីសង់ខ្ទមស្នាក់នៅដោយខ្លួនឯង ដាច់ពីប្រជាជនមូលដ្ឋាន។ គ្រាន់តែទៅដល់ គេប្រើឲ្យក្រុមគ្រួសារដែលទើបទៅដល់ថ្មីទាំងនោះច្រូតស្រូវទាំងយប់ទាំងថ្ងៃ។ តែក្នុង១គ្រួសារ គេចែកអង្ករឲ្យតែពីរកំប៉ុងប៉ុណ្ណោះ ដើម្បីដាំបាយហូបក្នុងមួយថ្ងៃ។ លុះដល់ដើមរដូវប្រាំង ឆ្នាំ១៩៧៦ ប្រជាជនថ្មីទាំងនោះចាប់ផ្តើមមានជំងឺ ដូច្នេះ គាត់ និងបងប្រុសរបស់គាត់ក៏បានចេញទៅរកត្រីនៅពេលយប់ ដើម្បីរកម្ហូបអាហារបន្ថែម ហើយក៏ត្រូវកម្មាភិបាលខ្មែរក្រហមចាប់ខ្លួន ដោយចោទពួកគាត់ថាជាខ្មាំង។ បងប្រុសគាត់ត្រូវបានគេចងស្លាបសេក និងវៃរហូតដល់សន្លប់នៅឯស្នាក់ការឃុំ ហើយអ្នកដាក់ពាក្យសុំក៏បានអង្វរកម្មាភិបាលនោះឲ្យឈប់វាយបងប្រុសគាត់។ បងប្រុសរបស់គាត់ក៏បានស្លាប់នៅក្នុងយប់នោះ ហើយមិនយូរប៉ុន្មាន ម្តាយ និងឪពុករបស់គាត់ក៏បានស្លាប់ដោយសារជំងឺដោយគ្មានថ្នាំព្យាបាល។ បងប្រុសម្នាក់ទៀតរបស់គាត់បានស្លាប់ទៀត នៅពេលដែលគាត់បានដឹងថាម្តាយរបស់ខ្លួនបានស្លាប់។ ក្នុងចំណោមមនុស្ស៧០ នាក់ដែលរស់នៅក្នុងសហករណ៍ជាមួយគាត់ពីដំបូងនៅសល់តែប្រហែល៣០ នាក់ប៉ុណ្ណោះ គិតត្រឹមរដូវដកស្ទូងក្នុងឆ្នាំ១៩៧៦។ អ្នកខ្លះស្លាប់ដោយសារ

ធ្វើការធ្ងន់បាក់កម្លាំង និងឈឺគ្មានថ្នាំព្យាបាល អ្នកខ្លះទៀតត្រូវបានគេយកទៅសម្លាប់ចោល។ មេដឹកនាំខ្មែរក្រហមបានបញ្ជាឲ្យអ្នកនៅរស់រែកសំណាប ជីកប្រឡាយ លើកទំនប់ ចាប់ពីម៉ោង៤ ទៀបភ្លឺ ដល់ម៉ោង៥ ល្ងាច សម្រាកហូបបាយថ្ងៃត្រង់១ម៉ោង ហើយធ្វើការបន្តពីម៉ោង៧ យប់ ដល់ម៉ោង១១ យប់ ទើបសម្រាក។ លុះដល់ដើមឆ្នាំ១៩៧៨ កម្មាភិបាលខ្មែរក្រហមបានចាប់ "អ្នកមានកំហុស" និង "ខ្មាំង" ជារៀងរាល់យប់[52]។

(២) មេដឹកនាំខ្មែរក្រហមបានបញ្ជាឲ្យអ្នកដាក់ពាក្យសុំ ដន ណាត (13-VSS-00316) ទោះបីជាលោកស្រីតូចចិត្តយ៉ាងខ្លាំងចំពោះវាសនារបស់ខ្លួន ហើយបានប្រកែកពីដំបូង ក៏ដោយ ជាចុងក្រោយលោកស្រីលែងប្រកែកតវ៉ា ដោយសារខ្លាចអង្គការយកទៅសម្លាប់ ឬថ្ងៃក្រោយត្រូវរៀបការជាមួយជនពិការ។ ពិធីរៀបការបានប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានសហករណ៍ ឈ្មោះ តាណាត និងមានការចូលរួមពីប្រធានកងបីបួននាក់ទៀត។ អ្នកដាក់ពាក្យសុំ បានរៀបការជាមួយបុរសឈ្មោះ គង់ បូ ជាទាហានខ្មែរក្រហម នៅម៉ោង៧ ព្រឹក ជាមួយអ្នកដទៃប្រាំគូទៀត។ ឪពុកម្ដាយ និងសាច់ញាតិមិនត្រូវបានគេអនុញ្ញាតឲ្យចូលរួមក្នុងកម្មវិធីនោះទេ។ នៅពេលយប់ ប្ដីប្រពន្ធមួយគូៗត្រូវបានគេចាត់ឲ្យទៅសម្រាកនៅក្នុងខ្ទមមួយមានកម្មាភិបាលខ្មែរក្រហមតាមដានមើលឲ្យប្រាកដ

---

[52] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1407 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈុំ ហុន ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ERN 01057540-42។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ ឯកសារ D219/503 កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឈុំ ហុន ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥។

ថា គូស្រករបានផ្សំដំណេកជាប្តីប្រពន្ធបន្ទាប់ពីបានរៀបការរួច។ គូស្រករណាដែលមិនព្រមរួមដំណេក ត្រូវគេយកទៅកសាង[53]។

(៣) ក្នុងឆ្នាំ១៩៧៨ លោកស្រី កប ញ៉េន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (13-VSS-00477) ត្រូវបានអង្គការបង្ខំឲ្យរៀបការជាមួយឈ្មោះ សន គីម ដែលគាត់មិនស្រឡាញ់គ្នាសោះ រស់នៅដល់ឆ្នាំ១៩៨១ ទើប សន គីមស្លាប់។ ដល់ឆ្នាំ១៩៨៦ អ្នកស្រី កប ញ៉េន រៀបការជាមួយប្តីឈ្មោះ រ៉េន ប្រាក់ និងរស់នៅជាមួយគ្នាដល់សព្វថ្ងៃ។ គាត់សុំកែតម្រូវឡើងវិញ ព្រោះកាលធ្វើពាក្យបណ្តឹងមុននោះ កប ញ៉េន ឈឺភ្លេចភ្លាំងច្រើន។ ឥឡូវ គាត់សុំកែតម្រូវអង្គហេតុ។ ថ្ងៃរៀបការហ្នឹងមានគូស្រករប្រាំមួយគូ ត្រូវបានគេរៀបចំនៅក្នុងភូមិរបស់អ្នកស្រី ដែលស្ថិតក្នុងខេត្តព្រៃវែង។ អ្វីដែលបានធ្វើឲ្យអ្នកស្រីរន្ធត់ខ្លាំង គឺបងប្អូនសាច់ញាតិគេហាមផ្តាច់មិនឲ្យចូលរួមដាច់ខាត មិនអនុញ្ញាតឲ្យមានភ្លេងប្រពៃណីទេ ឬសម្លៀកបំពាក់ប្រពៃណីក៏គ្មានទេ[54]។

(៤) ដោយសារការអត់អាហារ ឪពុកម្តាយរបស់អ្នកស្រី អិន សុភាព (13-VSS-00193) បានសុំអង្ករពីអ្នកភូមិក្បែរខាងនៅក្នុងខែកក្កដា ឆ្នាំ១៩៧៧។ កម្មាភិបាលខ្មែរក្រហមដែលបានឃើញគ្រួសារគាត់សុំអង្ករគេ បានចាប់អ្នកស្រី និងបងប្អូនរបស់អ្នកស្រីយកទៅដាក់គុកនៅមន្ទីរសន្តិសុខក្រាំងតាចាន់ក្នុងខេត្តតាកែវ ដើម្បីកសាង។ នៅក្រាំងតាចាន់ ពួកគាត់ត្រូវបានគេដាក់ច្រវ៉ាក់ ហើយវាយធ្វើបាបនឹងបំពង់ឫស្សី។ នៅពេលដែលគេវាយធ្វើបាបពួកគាត់ បងប្រុសរបស់អ្នកស្រីបានស្លាប់

---

[53] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1336 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជន ណាត ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ERN 01143710-11។

[54] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1527 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ កប ញ៉េន ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ ERN 01081266-67, 01133157-58។

ដោយសារមានរបួសធ្ងន់ធ្ងរនៅលើក្បាល។ ក្រោយមក បងប្អូនអ្នកស្រីផ្សេងទៀតត្រូវបានគេបញ្ជូនទៅមន្ទីរសន្តិសុខតាមាន់នៅខេត្តកំពត ដោយគេបានដាក់ខ្នោះដៃខ្នោះជើង នៅពេលដែលពួកគេមិនធ្វើការធ្ងន់។ នៅពេលរំដោះក្នុងឆ្នាំ១៩៧៩ ពួកគេនៅតែត្រូវបានគេយកទៅអប់រំកែប្រែនៅមន្ទីរសន្តិសុខជើងចាប ដែលពួកគេនៅតែទទួលបានអាហារហូបតិចតួច និងត្រូវបានបង្ខំឲ្យធ្វើការធ្ងន់នៅឡើយ[55]។

28. ដូចមានពន្យល់ពិស្តារនៅក្នុងឧបសម្ព័ន្ធ "ង" (ក្រុមដែលត្រូវបានកំណត់ជាគោលដៅ) និង "ច" (គោលនយោបាយសហឧក្រិដ្ឋកម្មរួមផ្សេងទៀត) ម្ចាស់បណ្តឹងឧទ្ធរណ៍បានទទួលរងព្យសនកម្ម ដែលជាលទ្ធផលដោយផ្ទាល់នៃការអនុវត្តសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ដែល អោ អាន ត្រូវបានចោទប្រកាន់ថា បានចូលរួមក្នុងការអនុវត្ត។ ចំពោះអ្វីដែលបានលើកឡើងខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមគោរពស្នើអង្គបុរេជំនុំជម្រះទទួលយកម្ចាស់បណ្តឹងឧទ្ធរណ៍ទាំងនេះជាដើមបណ្តឹងរដ្ឋប្បវេណី។

**ខ. ការសន្មតទុកជាមុនពីព្យសនកម្មរួម មានវិសាលភាពគ្របដណ្តប់លើសមាជិកគ្រប់រូបនៃក្រុម ឬសហគមន៍ជាក់លាក់ ដែលត្រូវបានគេកំណត់ជាគោលដៅនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ដោយមិនគិតពីទីកន្លែងរបស់ពួកគេ។**

29. ដីកាដែលរងការជំទាស់ក៏មានកំហុសក្នុងការដាក់កម្រិតលើការវិភាគភាពអាចទទួលយកបាន ត្រឹមតែឧក្រិដ្ឋកម្មនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ផងដែរ ដោយហេតុថា ជនរងគ្រោះ

[55] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1137 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អិន សុភាព ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤។

ដែលនៅក្រៅភូមិភាគនេះ គឺជាសមាជិកនៃសហគមន៍ ឬក្រុមដែលត្រូវបានគេកំណត់ជាគោលដៅតែមួយ ជាមួយនិងប្រជាជនដែលបានរងគ្រោះនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់)។

30. នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានទទួលស្គាល់នូវ "ការសន្មតទុកជាមុនពីការខូចខាតជាសមូហភាព" ដែលមានវិសាលភាពលាតសន្ធឹងដល់សមាជិកនៃក្រុម ឬសហគមន៍ដែលត្រូវបានគេធ្វើទុក្ខបុកម្នេញតែមួយ នៅពេលដែលឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ ដូចជាអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានចោទប្រកាន់[56]។ អនុលោមតាមការសន្មតទុកជាមុននេះ "ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានលើកឡើងថា គាត់គឺជាសមាជិកនៃក្រុម ឬសហគមន៍ដែលត្រូវបានគេកំណត់ជាគោលដៅតែមួយជាមួយនិងជនរងគ្រោះដោយផ្ទាល់ គឺព្យសនកម្មអាចជាព្យសនកម្មផ្លូវចិត្ត ដែលជនរងគ្រោះដោយប្រយោលបានទទួលរង *ដែលព្យសនកម្មនេះកើតចេញពីព្យសនកម្ម*ដែលជនរងគ្រោះផ្ទាល់បានទទួលរង[.]"[57]។ អង្គបុរេជំនុំជម្រះមានសម្អាងហេតុថា "នៅពេលដែលជនរងគ្រោះដោយប្រយោលជាសមាជិកនៃក្រុមមនុស្ស ឬសហគមន៍ណាមួយដែលក្លាយជាគោលដៅនៃការអនុវត្តគោលនយោបាយបក្សកុម្មុនីស្តកម្ពុជា *មិនមានភាពខុសគ្នា*

[56] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៨៣-៩៣។

[57] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៩៣ (បន្ថែមពាក្យសង្កត់ន័យ)។

*រវាងអ្វីដែលមានកើតឡើងចំពោះបុគ្គលម្នាក់ៗ និងអ្វីដែលបានកើតឡើងជារួមឡើយ*"[58]។ អង្គបុរេជំនុំជម្រះក៏យល់ឃើញថែមទៀតថា "វាជាការមិនត្រឹមត្រូវ ប្រសិនបើយើងពិនិត្យមើលការខូចខាតដែលបង្កដោយអំពើសហាវឃោរឃៅជាទ្រង់ទ្រាយធំ តែទៅលើមូលដ្ឋានជាបុគ្គល [...] អំពើសាហាវឃោរឃៅជាទ្រង់ទ្រាយធំ ដែលជាផលវិបាកនៃការអនុវត្តគោលនយោបាយជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំ ហើយដែលការអនុវត្តនោះទៅលើសហគមន៍ទាំងមូល ក៏ដូចជាទៅលើក្រុមជាក់លាក់នានា ព្រមទាំងបុគ្គលនៅក្នុងសហគមន៍នោះផងដែរ"[59]។ ដូច្នេះ ចំពោះការខូចខាតជាលក្ខណៈសមូហភាព អង្គបុរេជំនុំជម្រះមិនតម្រូវឲ្យមានភាពជិតគ្នាផ្នែករូបរាងកាយរវាងសមាជិកនៃក្រុមមនុស្ស ឬសហគមន៍គោលដៅតែមួយឡើយ។

31. ការអនុវត្តគោលការណ៍ស្ដីពី "ការខូចខាតជាសមូហភាព" ដោយអង្គបុរេជំនុំជម្រះមានលក្ខណៈស្រដៀងគ្នាជាមួយការអនុវត្តជាអន្តរជាតិ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានទទួលស្គាល់ថា "ព្យសនកម្មត្រូវតែជាលក្ខណៈរូបវ័ន្ត និងសមូហភាព"[60]។ គោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើឧក្រិដ្ឋ និងការរំលោភអំណាច ឆ្នាំ១៩៨៥

---

[58] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៨៨ (បន្ថែមពាក្យសង្កត់ន័យ)។

[59] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧០។

[60] *រឿងក្ដីរដ្ឋអាជ្ញាតទល់នឹង Thomas Lubanga Dyilo* ឯកសារ ICC-01/04-01/06-1432 សាលដីកាចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ លើបណ្ដឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា និងមេធាវីការពារប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង១ លើការចូលរួមរបស់ជនរងគ្រោះនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ កថាខណ្ឌ ៣៥។

របស់អង្គការសហប្រជាជាតិ ផ្តល់និយមន័យថា "ជនរងគ្រោះ" គឺជាបុគ្គលទាំងឡាយណា ទោះជាឯកត្តបុគ្គល ឬជាសមូហភាពក្តី ដែលបានទទួលរងអន្តរាយ[.]"[61]។ យោងតាមគោលការជាមូលដ្ឋានឆ្នាំ២០០៥ "មិនលើសពីនេះទៀត ទម្រង់នៃការធ្វើឲ្យក្លាជាជនរងគ្រោះនាសម័យទំនើប ជាពិសេសនៅពេលដែលត្រូវបានធ្វើឡើងប្រឆាំងនឹងមនុស្ស ក៏អាចត្រូវបានប្រព្រឹត្តឡើង*ប្រឆាំងនឹងក្រុមមនុស្សដែលត្រូវបានគេកំណត់គោលដៅជាសមូហភាព*ផងដែរ[.]"[62]។ ស្ថាប័នសិទ្ធិមនុស្សមួយចំនួនក៏បានទទួលស្គាល់ដែរថា ក្រុមមនុស្សដែលគេកំណត់គោលដៅជាសមូហភាពទាំងនេះ មានសិទ្ធិ និងអាចទទួលរងអន្តរាយ ដូច្នេះត្រូវធានាសំណងសម្រាប់ពួកគេ[63]។

---

[61] សេចក្តីប្រកាសស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច, សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ៤០/៣៤ អនុម័តនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ ឧបសម្ព័ន្ធ ក.១។

[62] គោលការណ៍ជាមូលដ្ឋាន និងសេចក្តីណែនាំស្តីពីសិទ្ធិទទួលបានសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាត, សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ៦០/១៤៧ អនុម័តនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥, បុព្វកថា (បន្ថែមពាក្យសង្កត់ន័យ)។

[63] *សូមមើលជាអាទិ៍* គណៈកម្មការសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិក, *មជ្ឈមណ្ឌលអភិវឌ្ឍន៍សិទ្ធិជនជាតិភាគតិច (កេនយ៉ា) និងក្រុមសិទ្ធិជនជាតិភាគតិចអន្តរជាតិ តាងនាមឲ្យក្រុមប្រឹក្សាសុខុមាលភាពអង់ដូរ៉ស់ តទល់នឹងប្រទេសកេនយ៉ា* ឯកសារលេខ ២៧៦/០៣ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ២៤៨ (គូសបញ្ជាក់ថា រដ្ឋមាន "កាតព្វកិច្ចកម្រិតខ្ពស់ ពាក់ព័ន្ធនឹងការចាត់វិធានការជាវិជ្ជមាន ដើម្បីការពារក្រុម និងសហគមន៍នានា ដូចជា សហគមន៍អង់ដូរ៉ស់នេះ")។ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, *យោបល់ទូទៅលេខ ២១ សិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការចូលរួមក្នុងជីវភាពខាងវប្បធម៌* ឯកសារ E/C.12/GC/21 ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ ៣៧ ("ជនជាតិដើមភាគតិចមានសិទ្ធិអនុវត្តសកម្មភាពជាសមូហភាពដើម្បីធានានូវការគោរពសិទ្ធិរបស់ខ្លួន ក្នុងការថែរក្សា គ្រប់គ្រង ការពារ និងអភិវឌ្ឍមរតកវប្បធម៌ ចំណេះវិជ្ជាប្រពៃណី និងការបង្ហាញពីទំនៀមទម្លាប់វប្បធម៌ [...] រដ្ឋភាគីត្រូវគោរពគោលការណ៍ទទួលបានការព្រមព្រៀងដោយសេរី ជាមុន និងផ្អែកលើព័ត៌មានគ្រប់គ្រាន់របស់ជនជាតិដើមភាគតិចក្នុងគ្រប់កិច្ចការទាំងអស់ដែលត្រូវបានគ្របដណ្តប់ដោយសិទ្ធិជាក់លាក់ទាំងនេះ")។ តុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក, *ករណីជនជាតិដើមភាគតិចគិច្ហវ៉ា (Kichwa) នៃអម្បូរ Sarayaku តទល់នឹងប្រទេសអេក្វាដ័រ*, សាលក្រម (អង្គសេចក្តី និងសំណង) ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌ ២៣១-៣២, ២៨៤ (បញ្ជាក់អះអាងថា "ច្បាប់អន្តរជាតិស្តីពីសហគមន៍ និងជនជាតិដើមភាគតិច ឬកុលសម្ព័ន្ធទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមទាំងនេះជាកម្មវត្ថុសមូហភាពនៃច្បាប់អន្តរជាតិ មិនត្រឹមតែទទួលស្គាល់ជាសមាជិកសហគមន៍ទាំងនោះ [...]ឡើយ"។ ក្រោយមកទៀត រកឃើញ

32. យោងតាមដីកាដំណោះស្រាយ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម អោ អាន គឺជាអ្នកទទួលខុសត្រូវចំពោះការវាយប្រហារនៅក្នុងភូមិភាគកណ្ដាល (ភូមិភាគឧត្ដរចាស់) ដែលផ្ដោតគោលដៅលើក្រុមមនុស្ស ឬសហគមន៍ជាក់លាក់ រាប់បញ្ចូលទាំងជនជាតិវៀតណាម ជនជាតិចាម និងអ្នកកាន់សាសនា ខ្មែរកម្ពុជាក្រោម "ប្រជាជនថ្មី" អតីតអ្នកជាប់ពាក់ព័ន្ធជាមួយរបប លន់ នល់ អ្នកដែលត្រូវគេសន្មតថាជាវណ្ណៈដែលគេមិនពេញចិត្ត (នាយទុន សក្ដិភូមិ ម្ចាស់ដី និងអនុជន) អ្នកដែលត្រូវគេចោទថាជាតិញសេអ៊ីអា និងកាហ្សេបេកម្មាភិបាល ប.ក.ក ដែលគេចោទថាធ្វើសកម្មភាពក្បត់ និងប្រជាជនពីភូមិភាគបូព៌ា[64]។ ដូចមាននៅក្នុងការសម្អាងហេតុរបស់អង្គបុរេជំនុំជម្រះ ការសន្មតទុកជាមុនពីការខូចខាតជាសមូហភាពដែលកើតចេញពីព្យសនកម្មដែលទទួលរងដោយជនរងគ្រោះផ្ទាល់នៅក្នុងភូមិភាគកណ្ដាល (ភូមិភាគឧត្ដរចាស់) លាតសន្ធឹងដល់សមាជិក*គ្រប់រូប*នៃក្រុមមនុស្ស ឬសហគមន៍គោលដៅជាក់លាក់ទាំងនេះ ដោយមិនគិតដល់ទីកន្លែងរបស់ពួកគេ។

33. នៅក្នុងដីកាដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតអន្ដរជាតិ ទទួលស្គាល់ដោយចេតនានូវគោលការណ៍ព្យសនកម្មជាសមូហភាពរបស់អង្គបុរេជំនុំជម្រះ ដោយសារគោលការណ៍នេះ

---

ថា ប្រទេសអេក្វាដរបានរំលោភបំពាន "សិទ្ធិក្នុងការទទួលបានទ្រព្យសម្បត្តិសមូហភាពរបស់ជនជាតិសារ៉ាយ៉ាគូ" និងសម្រេចឲ្យប្រទេសអេក្វាដរទទួលខុសត្រូវចំពោះជនជាតិទាំងនេះជាភាគីដែលទទួលរងការខូចខាត)។

[64] សំណុំរឿង ០០៤/០២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ២១៨។ សំណុំរឿងលេខ ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ៧, ១៦-១៧។ *សូមមើលផងដែរ* សំណុំរឿង ០០៤ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថខណ្ឌ ២១។

ទាក់ទងនឹងភាពអាចទទួលយកបាននៃដើមបណ្ដឹងរដ្ឋប្បវេណី ដោយបានអះអាងថា "ជនរងគ្រោះមិនផ្ទាល់ អាចទទួលរងព្យសនកម្មបែបនេះ ទោះបីជាគាត់គ្មានទំនាក់ទំនងជាគ្រួសារជាមួយនឹងជនរងគ្រោះផ្ទាល់ក៏ដោយ ពោលគឺឲ្យតែពួកគាត់ជាសមាជិកនៅក្នុងក្រុមគោលដៅតែមួយ ឬសហគមន៍តែមួយ"[65]។ ទោះបីជាយ៉ាងនេះក្ដី សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់លក្ខខណ្ឌដែលមានកំហុសថា សមាជិកដែលរស់នៅក្នុងក្រុម ឬសហគមន៍គោលដៅតែមួយ ត្រូវមានទីតាំងស្ថិតនៅក្នុងភូមិភាគកណ្ដាល (ភូមិភាគឧត្តរចាស់) ផ្ទាល់ ដោយច្រានចោលនូវលក្ខណៈជាសមូហភាពដែលជាចំណុចស្នូលនៃគោលការណ៍នេះ។

34. ក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤/២ គឺជាសមាជិកនៃក្រុមដែលគេបានកំណត់ជាគោលដៅដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងដីកាដំណោះស្រាយ ដូចរៀបរាប់ខាងក្រោម។

(១) នៅក្នុងឆ្នាំ១៩៧៥ លោក វ៉ែន វ៉ន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (11-VSS-00276) បានរៀបការយកប្រពន្ធជាជនជាតិវៀតណាម និងមានកូនជាមួយគ្នា។ ក្រោមរបបខ្មែរក្រហម គាត់ និងប្រពន្ធត្រូវបានគេចាត់តាំងឲ្យរកត្រី និងដាំស្លនៅក្នុងសហករណ៍បាក់ចិញ្ចៀន ក្នុងខេត្តពោធិ៍សាត់។ ក្នុងឆ្នាំ១៩៧៥ ជនជាតិវៀតណាមក្នុងតំបន់នេះត្រូវបានគេចាប់បញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ តែប្រពន្ធរបស់គាត់មិនព្រមចេញទៅជាមួយគេ ពីព្រោះគាត់ចង់នៅរួមរស់ជាមួយគ្រួសារ។ នៅដើមឆ្នាំ១៩៧៦ អ្នកដាក់ពាក្យ

[65] ដីកាដែលរងការជំទាស់ កថាខណ្ឌ ៣៥។

ស៊ុំត្រូវបានពួកខ្មែរក្រហមចោទថា "ក្បាលយួនខ្លួនខ្មែរ" ដោយសារគាត់រកត្រីមិនបានគ្រប់គ្រាន់។ គាត់ និងកូនៗទាំងអស់របស់គាត់ លើកលែងតែកូនពៅ ត្រូវបានអង្គការតម្រូវឱ្យរស់នៅបែកគ្នាពីប្រពន្ធរបស់គាត់។ កូនៗរបស់ពួកគេត្រូវបានគេបង្ខំឱ្យជ្រើសរើសថា តើត្រូវរស់នៅជាមួយអ្នកដាក់ពាក្យសុំ ឬចូលរួមជាមួយម្តាយជាជនជាតិវៀតណាមរបស់ខ្លួន។ កូនទាំងអស់លើកលែងតែកូនតូច រស់នៅជាមួយគាត់។ ក្រោយមក អង្គការបានឱ្យប្រពន្ធរបស់គាត់ទៅដកស្ទូងស្រូវនៅភូមិផ្សេង និងត្រូវបានអនុញ្ញាតឱ្យទៅជួបគ្រួសារតែពីរដងប៉ុណ្ណោះក្នុង១ខែ។ ក្នុងឆ្នាំ១៩៧៧ ប្រពន្ធ និងកូនពៅរបស់គាត់ ត្រូវបានគេយកទៅសម្លាប់នៅទួលកកោះជាមួយប្រជាជនប្រាំគ្រួសារទៀតដោយគេចោទថា មានការជាប់ពាក់ព័ន្ធជាមួយខ្មាំង ឬគិញយួន ឬជាខ្មាំងយួន ឬគិញយួនផ្ទាល់[66]។

(២) លោក ជិន សុខុម ជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (13-VSS-00647) ត្រូវបានអង្គការចាត់ឱ្យធ្វើការនៅក្នុងកងកុមារ ដែលគាត់ត្រូវបានគេតម្រូវឱ្យលើកភ្លឺស្រែឱ្យបាន២៥ ម៉ែត្រក្នុង១ថ្ងៃ។ អ្នកដាក់ពាក្យសុំត្រូវបានគេចាប់យកទៅឃុំឃាំងដោយគេចោទថាជាគិញយួន។ ក្នុងឆ្នាំ១៩៧៨ គាត់ និងសាច់ញាតិ រួមជាមួយប្រជាជនចិតសិបគ្រួសារទៀតដែលខ្មែរកម្ពុជាក្រោម ត្រូវបានគេបញ្ជូនទៅឃុំខ្នារទទឹង ស្រុកបាកានខេត្តពោធិ៍សាត់។ ពេលទៅដល់ឃុំខ្នារទទឹង ប្រជាជនទាំងនោះត្រូវបានគេប្រាប់ឱ្យទៅចូល

---

[66] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/111 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ វ៉ែន វ៉ន ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ ERN 00426923។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ ឯកសារ D118/192 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងជាដើមបណ្តឹងរដ្ឋប្បវេណី វ៉ែន វ៉ន ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ ERN 00986178, 00986180-82។

រួមប្រជុំ ដោយនៅពេលប្រជុំនោះគេបានបែងចែកឲ្យគ្រួសារខ្មែរឈរម្ខាង និងគ្រួសារខ្មែរក្រោមឈរម្ខាង។ កម្មាភិបាលខ្មែរក្រហមបានយកគ្រួសារដែលគេកំណត់អត្តសញ្ញាណថាជាខ្មែរក្រោមទៅសម្លាប់ចោល ដោយចោទថាជាយួន។ អ្នកដាក់ពាក្យសុំ និងម្ដាយរបស់គាត់គេចផុតពីការសម្លាប់ តែឪពុក បងស្រី បងប្រុស ឪពុកមា ម្ដាយមីង និងសាច់ញាតិផ្សេងទៀត សរុបទាំងអស់២០ នាក់ ត្រូវបានឈ្មោះម៉ី និងសម្បត្តិ យកទៅសម្លាប់នៅទីតាំងសម្លាប់ព្រៃក្របៅ[67]។

(៣) អ្នកស្រី អែល ម៉ើ ជាដើមបណ្ដឹងរដ្ឋប្បវេណី (13-VSS-00403) ជនជាតិចាម និងគ្រួសាររបស់អ្នកស្រី ត្រូវបានគេជម្លៀសដោយបង្ខំចេញពីភូមិកំណើតនៅក្នុងខេត្តកំពត ឲ្យទៅរស់នៅតាមសហករណ៍នៅកំពង់សោម និងក្រោយមក នៅខេត្តកំពង់ស្ពឺ។ ប្រធានសហករណ៍ បានឲ្យគាត់ និងប្ដីរបស់គាត់ធ្វើស្រែ "ទាំងយប់ទាំងថ្ងៃ"។ ពួកគេទទួលបានរបបអាហារស្ទើរតែហូបមិនគ្រប់ ដើម្បីរស់។ នៅដើមឆ្នាំ១៩៧៦ ប្ដីរបស់អ្នកដាក់ពាក្យសុំឈ្មោះ សំ ណះ បានស្លាប់ដោយសារការអត់អាហារ និងគ្មានថ្នាំព្យាបាលជំងឺ។ អ្នកដាក់ពាក្យសុំមិនត្រូវបានអនុញ្ញាតឲ្យទៅមើលប្ដីរបស់ខ្លួន ដែលបានស្លាប់នៅក្នុងមន្ទីរពេទ្យទេ ហើយគេក៏មិនអនុញ្ញាតឲ្យគាត់កប់សាកសពប្ដី និងកូនទាំងបីដែលក្រោយមកបានស្លាប់ដោយសារជំងឺ និងការអត់បាយ តាមប្រពៃណីខ្មែរឡើយ។ អ្នកដាក់ពាក្យសុំ ត្រូវបានគេបង្ខំឲ្យហូបសាច់ជ្រូក ប្រឆាំងនឹងជំនឿសាសនារបស់គាត់។ អ្នកនៅជាមួយគាត់ ដែលបាន

[67] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1412 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជិន សុខុម ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ERN 01098658-59។

ព្យាយាមគោរពប្រតិបត្តិសាសនារបស់ខ្លួន ត្រូវបានគេយកទៅសម្លាប់។ ក្រោយមកក្នុងឆ្នាំ ១៩៧៦ កម្មាភិបាលខ្មែរក្រហមបានយកក្មួយរបស់គាត់បីនាក់ទៅសម្លាប់ ដោយសារពួកគេបានលួចដំឡូងហូប នៅពេលដែលពួកគេអត់បាយហូប។ ជារួម អ្នកដាក់ពាក្យសុំបានបាត់បង់សមាជិកគ្រួសារសរុបចំនួនប្រាំបីនាក់ក្នុងសម័យខ្មែរក្រហម[68]។

(៤) អ្នកដាក់ពាក្យសុំឈ្មោះ ម៉ាន ស្លេះ (16-VSS-00015) ជាជនជាតិចាម ត្រូវបានពួកខ្មែរក្រហមចាប់ខ្លួនជាមួយឪពុក និងអ្នកដទៃទៀតនៅក្នុងភូមិកំណើតរបស់គាត់ គឺភូមិទីប្រាំ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ដោយចោទពួកគាត់ថាជាខ្មាំង នៅក្នុងខែមេសា ឆ្នាំ១៩៧៥។ គាត់ និងអ្នកភូមិចាមប្រហែលជា៥០ នាក់ ទៅ៦០ នាក់ទៀត ត្រូវបានគេចាប់ចងនឹងខ្សែពួរ យកទៅឃុំឃាំងអស់រយៈពេល១០ ថ្ងៃ។ ក្រោយមក គេបានដោះលែងអ្នកទាំងអស់នោះមកវិញ ទុកតែប្រាំនាក់ប៉ុណ្ណោះ។ ឪពុករបស់គាត់ ដែលជាប្រធានភូមិ បងជីដូនមួយគាត់ លី មែន និងពីរនាក់ទៀត ត្រូវបានគេចាប់ដាក់រទេះសេះ ហើយដឹកយកទៅស្នាក់ការស្រុក។ ក្រោយមក បុរសម្នាក់ឈ្មោះ សុង បាននិយាយប្រាប់អ្នកដាក់ពាក្យសុំថា ឪពុករបស់គាត់ និងអ្នកដទៃទៀត ត្រូវបានយកទៅឃុំឃាំងនៅអូរបាក់នឹម ស្ថិតក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ អ្នកទាំងនោះបានបាត់ខ្លួនរហូត ហើយគេសន្និដ្ឋានថាពួកគាត់ត្រូវបានគេសម្លាប់ចោលអស់ហើយ។ ក្រោយពីហ្នឹងមក គេមិនអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំ និងអ្នកភូមិដទៃទៀតគោរពប្រតិបត្តិសាសនារបស់ខ្លួនឡើយ ហើយការចាប់

[68] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1241 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឯល ម៉ើ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ ERN 01145390។

មនុស្សយកទៅឃុំឃាំងមានជាបន្ត រហូតដល់អ្នកភូមិបាននាំគ្នាបះបោរប្រឆាំងនឹងពួកខ្មែរក្រហម ហើយអ្នកបះបោរទាំងអស់ត្រូវបានចាប់ខ្លួនយកទៅឃុំឃាំងឲ្យនៅក្នុងវត្តជ្រៃ និងឡូដាក់ថ្នាំនៅក្នុងស្រុកក្រូចឆ្មារ។ នៅចុងឆ្នាំ១៩៧៥ ក្រោយពីគេបានដោះលែងពីកន្លែងឃុំឃាំង អ្នកដាក់ពាក្យសុំ ព្រមទាំងប្រពន្ធ និងកូនរបស់គាត់ ត្រូវបានគេបង្ខំឲ្យផ្លាស់ទៅនៅភូមិសូភាស ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ចំណែកសមាជិកគ្រួសារដទៃទៀត រួមមានម្តាយ និងប្អូនបីនាក់ទៀត ត្រូវបានគេជម្លៀសទាំងបង្ខំឲ្យនៅភូមិផ្សេង ហើយក្រោយមក នៅចុងឆ្នាំ១៩៧៦ ពួកគាត់ត្រូវបានគេដឹកតាមកាណូតយកទៅសម្លាប់នៅបឹងកញ្ចុះនៅក្នុងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម[69]។ ពេញរបបខ្មែរក្រហម អង្គការខ្មែរក្រហមមិនអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំសូត្រធម៌ ឬប្រើភាសារបស់ខ្លួនទេ ហើយមានពេលខ្លះ គេបានបង្ខំគាត់ឲ្យហូបសាច់ជ្រូក[70]។

(៥) ក្នុងឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហមបានឲ្យអ្នកដាក់ពាក្យសុំ ខៀវ នី (13-VSS-00610) រស់នៅជាមួយខ្មែរក្រោមដទៃទៀត នៅក្នុងសហករណ៍រំលេចស្ថិតក្នុងភូមិរំលេច ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់។ នៅទីនោះ គាត់បានរស់នៅបែកបាក់ពីឪពុកម្តាយ និងត្រូវគេបញ្ជូនទៅធ្វើការក្នុងកងចល័តខ្មែរក្រោម និងនៅតាមទីកន្លែងផ្សេងទៀត ចំណែកឪពុកម្តាយ និងបងប្អូនរបស់គាត់ធ្វើការនៅក្នុងសហករណ៍ខ្នារទទឹង ស្ថិតក្នុងភូមិខ្នារទទឹង

---

[69] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1858 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ាន ស្មេះ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01307057-59។

[70] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D219/792.1.4 ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/២ ចុះថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01452745-46។

ឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់។ ក្នុងឆ្នាំ១៩៧៧ អ្នកដាក់ពាក្យសុំបានទទួលដំណឹងពីអ្នកស្គាល់គ្នាដែលទើបត្រឡប់មកពីខ្នារទទឹងៗថា ពួកខ្មែរក្រោមត្រូវបានគេបញ្ជូនយកទៅសម្លាប់នៅព្រៃក្របៅ និងទួលសេះញ៉ូវ។ មួយសប្តាហ៍ក្រោយមក មេកងរបស់គាត់បានប្រកាសថា អ្នកណាមានឪពុក ឬម្តាយជាខ្មែរក្រោម អាចទៅរស់នៅជួបជុំឪពុកម្តាយវិញនៅខ្នារទទឹង ហើយអ្នកដាក់ពាក្យសុំក៏បានវិលត្រឡប់ទៅរស់នៅខ្នារទទឹងវិញ។ កម្មាភិបាលខ្មែរក្រហមបានប្រាប់ឲ្យគាត់រស់នៅទីនោះ តែមិនឲ្យគាត់ចូលរួមជាមួយកងចល័តរបស់ខ្លួនវិញទេ។ នៅទីនោះបានប្រហែលពីរសប្តាហ៍ អ្នកដាក់ពាក្យសុំបានឃើញយោធាខ្មែរក្រហមចាប់ផ្តើមជ្រើសរើសយកខ្មែរក្រោម និងវៀតណាមទៅសម្លាប់នៅទួលសេះញ៉ូវ និងព្រៃក្របៅរាល់ថ្ងៃរាល់យប់។ ជាចុងក្រោយ ក្នុងឆ្នាំ១៩៧៨ ឪពុក និងបងប្រុសពីរនាក់របស់អ្នកដាក់ពាក្យសុំ ដែលជាខ្មែរក្រោម ត្រូវបានគេចាប់យកទៅសម្លាប់នៅព្រៃក្របៅ។ សាច់ញាតិរបស់អ្នកដាក់ពាក្យសុំប្រហែលជា៧០ នាក់ ត្រូវបានគេយកទៅសម្លាប់នៅទីតាំងសម្លាប់ទួលសេះញ៉ូវ និងព្រៃក្របៅ[71]។

(៦) អ្នកដាក់ពាក្យសុំ ឈ្មោះ សុន ឯម (14-VSS-00170) បានបាត់បង់ឪពុក ឪពុកធំ និងសាច់ញាតិសាមសិបនាក់ទៀត ក្នុងរបបខ្មែរក្រហម។ ប្រហែលជាក្នុងខែមិថុនា ឆ្នាំ១៩៧៧ ឪពុករបស់អ្នកដាក់ពាក្យសុំ ឈ្មោះ សុត ចែត ដែលជាកម្មាភិបាលខ្មែរក្រហមទទួលបន្ទុកលើរោងចក្រឧស្សាហកម្មទាំងអស់នៅក្នុងខេត្តបាត់ដំបង និងឪពុកធំរបស់គាត់ឈ្មោះ

[71] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1400 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ខៀវ នី ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ERN 01103617។

សាយ ដែលជាប្រធានមន្ទីរភូមិភាគ ត្រូវបានចាប់ខ្លួន បញ្ជូនទៅភ្នំពេញ ហើយ សន្និដ្ឋាន ត្រូវគេសម្លាប់នៅក្នុងការបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យ និងត្រូវបានជំនួស ដោយកម្មាភិបាលមកពីភូមិភាគនិរតី។ ពួកគេទាំងពីរនាក់ត្រូវបានចោទថាជាជនក្បត់ និង ជាភ្នាក់ងារសេអ៊ីអា។ ប្រហែលជាពីរសប្តាហ៍ក្រោយការចាប់ខ្លួនអ្នកទាំងពីរ អ្នកដាក់ពាក្យ សុំ ដែលជានីរសាខ្មែរក្រហមនៅមន្ទីរ៥៦០ របស់ភូមិភាគ ដែលស្ថិតក្នុងខេត្តបាត់ដំបង ត្រូវ បានចោទថាជាជនក្បត់ ដោយអង្គការបានដកលោកចេញពីតំណែង ហើយបញ្ជូនឱ្យទៅ រៀនសូត្រ និងបង្ខំឱ្យធ្វើការធ្ងន់នៅភ្នំពេញ។ ប្រហែលជាក្នុងអំឡុងពេលនោះដែរ អ្នកនៅ ក្រោមបង្គាប់ និងសាច់ញាតិរបស់ឪពុក និងឪពុកធំ របស់អ្នកដាក់ពាក្យសុំ ត្រូវបានគេ កំណត់ជាគោលដៅ។ ក្រោយមក ណៃម សារ៉ង ដែលត្រូវជានក្មួយស្រីរបស់អ្នកដាក់ពាក្យ សុំ បានប្រាប់គាត់ថា សាច់ញាតិគាត់ប្រហែលជា៣០ នាក់ ដែលរស់នៅស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ត្រូវបានគេយកទៅសម្លាប់ និង/ធ្វើទារុណកម្ម ដោយគេចោទថាជាជនក្បត់ ឬស្លាប់ដោយសារការអត់អាហារ[72]។

(៧) ក្នុងឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំ ឈ្មោះ គន់ សុខ (11-VSS-00120) គ្រួសាររបស់គាត់ និងអ្នកភូមិដទៃទៀត ត្រូវបានគេកោះហៅទៅចូលរួមប្រជុំជាមួយកម្មាភិបាលខ្មែរក្រហម នៅភូមិតាស្អាង ឃុំកំពង់ចំឡង ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។ នៅកន្លែងប្រជុំ កម្មាភិបា លនោះបានស្រង់ព័ត៌មានអំពីប្រវត្តិរបស់ប្រជាជនគ្រប់រូប ស្រាវជ្រាវរកអ្នកដែលធ្លាប់ធ្វើ

---

[72] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D118/249 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណី សុន ឯម ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៤ ERN 01034083, 01034085, 01034090-93។

ការជាមន្ត្រីរាជការ ឬទាហានក្នុងសម័យសាធារណរដ្ឋខ្មែរ ឬរបបលន់ នល់។ ប្ដីរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ រដ្ឋ ពុទ្ធ ជាអតីតទាហាន ឪពុកឈ្មោះ គន អ៊ឹម និងប្រជាជនប្រហែលជា២០ នាក់ទៀត ត្រូវបានកត់ឈ្មោះនៅក្នុងបញ្ជីដែលរៀបចំដោយកម្មាភិបាលខ្មែរក្រហមនោះ។ អ្នកដែលមានឈ្មោះនៅក្នុងបញ្ជីទាំងអស់ត្រូវបានត្រូវបានគេយកទៅ "រៀនសូត្រ"។ ចាប់តាំងពីពេលនោះមក ប្ដី ឪពុក បងប្រុសរបស់អ្នកដាក់ពាក្យសុំ និងអ្នកភូមិដទៃទៀតបាត់ដំណឹងរហូត។ ក្រោយពេលគេចាប់អ្នកទាំងនោះទៅបាត់អស់ ក្រុមគ្រួសាររបស់ពួកគេត្រូវបានគេជម្លៀសជាច្រើនលើកឲ្យទៅរស់នៅតាមសហករណ៍ និងការដ្ឋានផ្សេងៗដោយមិនឲ្យបាយហូបទេ។ ពួកគេត្រូវបានតម្រូវឲ្យធ្វើការងារធ្ងន់ ដូចជាការលើកថ្នល់លើកប្រព័ន្ធភ្លឺស្រែ ធ្វើស្រែ និងបុកស្រូវ (៣០ តៅក្នុង១ថ្ងៃ) ពេញមួយថ្ងៃៗដោយគ្មានពេលសម្រាក។ គេចែកបបររាវៗឲ្យហូបម្នាក់តែពីរវែកប៉ុណ្ណោះ។ ចុងក្រោយ ក្នុងឆ្នាំ១៩៧៧ ពួកខ្មែរក្រហមបានប្រាប់ឲ្យអ្នកពាក្យសុំ រៀបការជាមួយអ្នកដទៃប្រាំបីគូទៀត។ នៅក្នុងពិធីរៀបការ ប្ដីប្រពន្ធបានឡើងប្ដេជ្ញាគោរពតាមបញ្ជាអង្គការ ដែលបានប្រាប់ពួកគេឲ្យបង្កើតកូនឲ្យអង្គការ។ នៅពេលយប់ ពួកខ្មែរក្រហមបានតាមដានអ្នកដាក់ពាក្យសុំ ចង់ដឹងថា តើគាត់ និងប្ដីគាត់នៅចុះសម្រុងជាមួយគ្នាដែរឬអត់។ អ្នកដែលមិននៅចុះសម្រុងនឹងគ្នាត្រូវគេយកទៅសម្លាប់ចោល។ លុះដល់ព្រឹកឡើង ប្រធានសហករណ៍សួរអ្នកដាក់ពាក្យសុំ

ថា តើគាត់បានរួមដំណេកជាមួយប្ដីឬអត់យប់មិញ ហើយដោយសារភ័យខ្លាចគេធ្វើបាប គាត់បានឆ្លើយថា គាត់បានរួមដំណេក[73]។

(៨) ក្រោមរបបខ្មែរក្រហម ពីដំបូង អ្នកដាក់ពាក្យសុំ ហាស់ ដា (11-VSS-00224) បានរស់នៅជួបជុំជាមួយគ្រួសាររបស់គាត់នៅឯស្រុកកំណើតក្នុងភូមិត្រពាំងបុណ្យ ឃុំព្រៃគគីរ ស្រុកចន្ទ្រា ខេត្តស្វាយរៀង។ ក្នុងឆ្នាំ១៩៧៥ គ្រួសាររបស់គាត់ត្រូវបានគេជម្លៀសឲ្យទៅនៅភូមិដូនតី ឃុំទួលស្ដី ស្រុកចន្ទ្រា ខេត្តស្វាយរៀង។ លុះដល់ឆ្នាំ១៩៧៧ អ្នកដាក់ពាក្យសុំត្រូវបានគេបង្ខំឲ្យទៅរស់នៅភូមិជ្រៃ ឃុំឈ្វាង ស្រុកក្រោលគោ ខេត្តស្វាយរៀង ដោយគេបានឲ្យគាត់ធ្វើការនៅក្នុងកងកុមារ។ ក្នុងឆ្នាំ១៩៧៨ អ្នកដាក់ពាក្យសុំត្រូវបានគេបង្ខំឲ្យផ្លាស់ទីលំនៅដោយការដើរ ជិះសាឡាង និងរទេះភ្លើងទៅដំណាក់ឈើក្រំ ខេត្តពោធិ៍សាត់។ គាត់បានស្នាក់នៅទីនោះពីរថ្ងៃពីរយប់ ទើបគេឲ្យគាត់ធ្វើការនៅក្នុងកងកុមារ ដោយគេបង្ខំឲ្យរែកដីលើកប្រឡាយ១៧ មេសា ទាំងគ្មានអាហារហូបគ្រប់គ្រាន់។ ប្រហែលជានៅពេលនោះហើយ ដែលឪពុក ម្ដាយដែលកំពុងមានផ្ទៃពោះ និងបងប្អូនបង្កើត០៦នាក់ ក្នុងចំណោមបងប្អូនទាំង០៨នាក់ ដែលសុទ្ធសឹងតែត្រូវបានជម្លៀសពីភូមិភាគបូព៌ា ត្រូវបានគេ

[73] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/260 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ត់ន សុខ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ ERN 00516240-42។ សំណុំរឿង ០០៤/២ ឯកសារ D5/260.1 ឧបសម្ព័ន្ធ១៖ ព័ត៌មានបន្ថែមអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ ERN 00581330-32។

យកទៅសម្លាប់ចោលនៅដំណាក់ឈើក្រំក្នុងខេត្តពោធិ៍សាត់ ដោយចោទថាមានក្បាលយួន ខ្លួនខ្មែរ[74]។

(៩) ទិត្យ អាម ដែលត្រូវជាបងប្រុសរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ ប៊ុន សារិន (15-VSS-00063) គឺជាគ្រូពេទ្យយោធា (ជំនាញវះកាត់) ខ្មែរក្រហមម្នាក់ដែលប្រចាំការនៅវត្តនិរោធ (ច្បារអំពៅ) ក្នុងទីក្រុងភ្នំពេញ។ នៅក្នុងខែសីហា ឆ្នាំ១៩៧៨ ទិត្យ អាម បានទៅជួបអ្នកដាក់ពាក្យសុំនៅភូមិពាយនាយ ឃុំក្រាំងស្វាយ ស្រុកព្រះស្ដេច ខេត្តព្រៃវែង។ ក្រោយពីនោះមក ពួកមេដឹកនាំខ្មែរក្រហមបានចាប់ផ្ដើមប្រមូលទាហានភូមិភាគបូព៌ាទាំងអស់ ដែលពួកគេយល់ថាមានខ្សែរយៈជាមួយ សោ ភឹម យកទៅសម្លាប់។ នៅពេលនោះ ទិត្យ អាម ត្រូវបានគេយកទៅសម្លាប់ចោល។ មិនយូរប៉ុន្មានក្រោយមក បងប្រុសម្នាក់ទៀតរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ ប៊ុន ប៉ោយ និងគ្រួសាររបស់គាត់ ត្រូវបានគេជម្លៀសដោយបង្ខំចេញពីខេត្តស្វាយឲ្យទៅនៅខេត្តពោធិ៍សាត់។ លុះដល់ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៩ ពួកខ្មែរក្រហមបានចាប់បញ្ជូនអ្នកដែលគេជម្លៀសពីភូមិភាគបូព៌ាទៅសម្លាប់ក្នុងព្រៃស្តុកខ្លានៅខេត្តពោធិ៍សាត់។ កម្មាភិបាលខ្មែរក្រហមបានសម្លាប់ ប៊ុន ប៉ោយ ប្រពន្ធ ម្ដាយក្មេក និងកូនរបស់គាត់ពីរនាក់នៅថ្ងៃនោះតែម្ដង[75]។

---

[74] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/145 ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ហាស់ ដា ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ ERN 00434318។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ ឯកសារ D5/145.1 ឧបសម្ព័ន្ធ១៖ ព័ត៌មានបន្ថែមអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១ ERN 00940132-33។

[75] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1757 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៊ុន សារិន ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ ERN 01236270-71។

(10) ក្នុងខែមេសា ឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំ អ្នកស្រី ស្វាយ ណេត (14-VSS-00196) រួមទាំងប្តី និងកូនទាំងប្រាំពីរនាក់ ត្រូវបានគេបង្ខំឲ្យចេញពីភ្នំពេញទៅស្រុកកំណើតប្តីរបស់គាត់នៅភូមិអង្គរផ្តៀក ឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ។ ពេលទៅដល់ភ្លាម គ្រួសាររបស់គាត់ត្រូវចាត់ទុកជា "អ្នក១៧ មេសា" ដូច្នេះគ្រួសាររបស់អ្នកស្រី ត្រូវបានគេធ្វើទុក្ខបុកម្នេញនៅទីនោះ។ អង្គការបានបំបែកប្រជាជនថ្មី និងប្រជាជនមូលដ្ឋានដោយឡែកពីគ្នា និងបានឲ្យពួកប្រជាជនថ្មីរស់នៅក្នុងសហករណ៍ដោយឡែកពីប្រជាជនចាស់ គឺសហករណ៍តាពោនស្ថិតក្នុងភូមិតាពោន ឃុំសំរោង ស្រុកសំរោង។ ប្តីរបស់អ្នកដាក់ពាក្យសុំត្រូវបានគេចាត់តាំងឲ្យធ្វើការងារយ៉ាងធ្ងន់ធ្ងរនៅក្នុងកងចល័ត ដូចជាកាប់គាស់ដីលើកទំនប់ជីកប្រឡាយ។ ទោះបីជាគាត់ធ្វើការធ្ងន់ប៉ុណ្ណាក៏ដោយ គេឲ្យហូបតែបបរមួយវែកពីរវែកប៉ុណ្ណោះ។ អ្នកដាក់ពាក្យសុំត្រូវបានគេបង្ខំឲ្យរែកដីលើកប្រព័ន្ធភ្លឺស្រែ ជីកប្រឡាយ រែកដី និងធ្វើការងារផ្សេងៗទៀត ចំណែកកូនៗរបស់អ្នកដាក់ពាក្យសុំ ទោះបីជាគេនៅក្មេងយ៉ាងណាក្តី ក៏ត្រូវបានគេតម្រូវឲ្យធ្វើការដូចមនុស្សធំពេញវ័យដែរ។ លុះដល់រដូវវស្សា ឆ្នាំ១៩៧៧ ស្ថានភាពរស់នៅរបស់អ្នកដាក់ពាក្យសុំ កាន់តែលំបាកវេទនាជាងមុនទៅទៀត ដោយគេឲ្យធ្វើការងារទាំងថ្ងៃទាំងយប់ជាច្រើនម៉ោង ស្ទើរតែគ្មានពេលទំនេរ ឯអាហារហូបចុកគឺត្រូវបានកាត់បន្ថយជាងមុនទៅទៀត។ ក្នុងរយៈពេលតែមួយខែប៉ុណ្ណោះ គឺក្នុងខែសីហា ឆ្នាំ១៩៧៧ ប្តី និងកូន០៥នាក់ របស់អ្នកស្រី បានស្លាប់ដោយជំងឺអត់អាហារនៅក្នុងសហករណ៍ ភូមិអង្គរផ្តៀក ឃុំជុំរះប៉ែន ស្រុកសំរោង ខេត្តតាកែវ។ មុនពេលប្តីស្លាប់ គាត់បានទៅមើលប្តីរបស់គាត់នៅក្នុងមន្ទីរពេទ្យ។ អ្នកស្រីរន្ធត់យ៉ាងខ្លាំងនៅពេលបានឃើញប្តីរ

បស់ខ្លួនមានរាងកាយស្គាំងស្គមមានតែស្បែកដណ្ដប់ឆ្អឹង និងដំបៅពេញខ្នង។ ពេលនោះប្ដីអ្នកស្រីបានប្រាប់អ្នកស្រីថា ពួកខ្មែរក្រហមបានយកគាត់ចេញពីពេទ្យទៅវាយធ្វើទារុណកម្ម និងសួរចម្លើយ ហើយក៏បានឆែកឃើញកាតទាហានលន់ នល់របស់គាត់[76]។

(១១) អ្នកដាក់ពាក្យសុំ អ្នកស្រី សៅ គិមសៀង **(16-VSS-00077)** ពណ៌នាថា នៅពេលដែលគេបង្ខំឲ្យគាត់ចេញពីផ្ទះនៅភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់បានឃើញសាកសពមុស្សប្រុស ស្រី កុមារ និងទាហានជាច្រើននៅតាមផ្លូវ[77]។ អ្នកដាក់ពាក្យសុំត្រូវបានគេជម្លៀសឲ្យទៅនៅភូមិព្រៃក្រឡា នៅតានីទូកមាស ក្នុងខេត្តកំពត ប៉ុន្តែកូនប្រុសអាយុ១៦ ឆ្នាំ និងកូនស្រីគាត់អាយុ១៤ ឆ្នាំ ត្រូវបានពួកខ្មែរក្រហមចាប់យកទៅ និងបង្ខំឲ្យចូលរួមធ្វើការក្នុងកម្លាំងការងារដោយបង្ខំសម្រាប់យុវជន និងយុវនារី។ លុះដល់ឆ្នាំ១៩៧៧ លោកស្រី សៅ ត្រូវបានពួកខ្មែរក្រហមបង្ខំឲ្យរស់នៅក្នុងភូមិមួយទៀត គឺភូមិគគីរបែកជាមួយឪពុក ម្ដាយធំ ជីដូនមួយ និងកូនរបស់គាត់ទាំងប្រាំនាក់[78]។ ដល់ប្រហែលជាពាក់កណ្ដាលឆ្នាំ អ្នកដាក់ពាក្យសុំបានឃើញពួកខ្មែរក្រហមចាប់យកម្ដាយធំ ជីដូនមួយ និងកូនគាត់បីនាក់ទៅសម្លាប់។ លុះដល់ឆ្នាំ១៩៧៩ អ្នកដាក់ពាក្យសុំបានជួបបងថ្លៃស្រីនៅភូមិសង្កែ ក្នុងខេត្តបាត់ដំបង ទើបដឹងថា បងប្រុស និងក្មួយប្រុសរបស់គាត់ត្រូវបានពួកខ្មែរក្រហម

[76] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1773 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស្វាយ ណេត ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ERN 01187359-60។

[77] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1920 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សៅ គិមសៀង ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៦ ERN 01374172។

[78] ឯកសារ D5/1920 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សៅ គិមសៀង ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ERN 01374172។

សម្លាប់ចោល ដោយសារពួកគេជាប់ពាក់ព័ន្ធជាមួយរបប លន់ នល់។ ក្រោយពីបងប្រុស និងក្មួយប្រុសគាត់ស្លាប់ទៅ បងថ្លៃស្រី និងចៅស្រីគាត់បីនាក់បានរត់គេចខ្លួនទៅរស់នៅភូមិសង្កែ ដើម្បីលាក់អត្តសញ្ញាណ និងនិន្នាការជាមួយរបប លន់ នល់។ ពួកយោធាខ្មែរក្រហមបានវាយធ្វើទារុណកម្មគាត់ ដើម្បីបង្ខំឱ្យគាត់ឆ្លើយសារភាពថាគាត់ជាប្រពន្ធនាយទាហានជាន់ខ្ពស់ ដោយរើគាត់នឹងចប គម្រាមចាប់រំលោភចៅស្រីគាត់ និងបង្ខំឱ្យគាត់ធ្វើការងារធ្ងន់ធ្ងរ[79]។

(១២) មុនសម័យខ្មែរក្រហម អ្នកដាក់ពាក្យសុំ លោក ខេវន ឡេងសូ (10-VSS-00319) គឺជាអធិការនគរបាលជាតិម្នាក់នៅភ្នំពេញ[80]។ លុះដល់សម័យខ្មែរក្រហម អ្នកដាក់ពាក្យសុំ និងគ្រួសារ ត្រូវបានពួកខ្មែរក្រហមបង្ខំឱ្យចេញពីផ្ទះរបស់ខ្លួននៅទីក្រុងភ្នំពេញ ហើយក្រោយមក ត្រូវបានបញ្ជូនទៅរស់នៅទីតាំងជាច្រើនកន្លែងនៅក្នុងខេត្តកណ្ដាល និងខេត្តកំពង់ចាម[81]។ បងប្រុស និងឪពុកធំរបស់អ្នកដាក់ពាក្យសុំត្រូវពួកខ្មែរក្រហមយកទៅខេត្ត

---

[79] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1920 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សៅ គិមសៀង ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ERN 01374172។

[80] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1916 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សូ ខុងឡេង ហៅខេវន ឡេងសូ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ERN 00569722។

[81] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1916 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សូ ខុងឡេង ហៅខេវន ឡេងសូ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ERN 00569722-23។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ ឯកសារ D5/1916/1 របាយការណ៍ពីផ្នែកគាំពារជនរងគ្រោះ។

កំពង់ចាម ហើយបងប្រុសគាត់ត្រូវពួកខ្មែរក្រហមសម្លាប់[82]។ កាលពីពេលដែលអ្នកដាក់ពាក្យរស់នៅតំបន់ក្បាលទឹកក្នុងខេត្តព្រៃវែង ពួកយោធាខ្មែរក្រហមបានវាយធ្វើបាបនឹងពូថៅ និងសួរចម្លើយអំពីអត្តសញ្ញាណរបស់គាត់[83]។ បន្ទាប់ពីគាត់បានឆ្លើយសារភាពថាគាត់ធ្លាប់ធ្វើជាប៉ូលីស ពួកទាហានខ្មែរក្រហមបានយករណារមកគម្រាមគាត់ មុនពេលគាត់សន្លប់បាត់ស្មារតី។ នៅពេលអ្នកដាក់ពាក្យសុំ បានជាពីឈឺដោយសារការវាយដំ ពួកខ្មែរក្រហមបានបង្ខំគាត់ឲ្យទៅនៅខេត្តក្រចេះ ក្រោយមកទើបគេបញ្ជូនគាត់ឲ្យទៅធ្វើការងារដោយបង្ខំនៅសហករណ៍ពីរទៀត[84]។ ដោយសារអ្នកដាក់ពាក្យសុំធ្លាប់ធ្វើអធិការប៉ូលីស ហើយគ្រួសារគាត់ជាអ្នកភ្នំពេញ ពួកខ្មែរក្រហមបានកំណត់ពួកគាត់ជាគោលដៅដោយសារពួកគេជាប់ពាក់ព័ន្ធជាមួយសម័យលន់ នល់ និងចាត់ទុកពួកគាត់ជា “ប្រជាជនថ្មី”។ ពួកគេបានក្លាយជាកម្មវត្ថុនៃការងារដោយបង្ខំ ហើយពួកគេមួយចំនួនត្រូវបានសម្លាប់ស្របតាមគោលនយោបាយទូទាំងប្រទេសរបស់បក្សកុម្មុយនីស្តកម្ពុជា។

---

[82] ឯកសារ D5/1916 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សូ ខុងឡេង ហៅខេវន ឡេងសូ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ERN 00569724។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ ឯកសារ D5/1916/1 របាយការណ៍ពីផ្នែកគាំពារជនរងគ្រោះ។

[83] ឯកសារ D5/1916 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សូ ខុងឡេង ហៅខេវន ឡេងសូ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ERN 00569723។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ ឯកសារ D5/1916/1 របាយការណ៍ពីផ្នែកគាំពារជនរងគ្រោះ។

[84] ឯកសារ D5/1916 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សូ ខុងឡេង ហៅខេវន ឡេងសូ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ERN 00569723-24។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ ឯកសារ D5/1916/1 របាយការណ៍ពីផ្នែកគាំពារជនរងគ្រោះ។

(១៣) ឡុង ពាន ត្រូវជាប្អូនប្រុសរបស់អ្នកដាក់ពាក្យសុំ ឡុង ផាង (11-VSS-00182) ត្រូវបានពួកខ្មែរក្រហមចាប់ខ្លួននៅឯការដ្ឋានមួយស្ថិតក្នុងខេត្តក្រចេះ ពីព្រោះគាត់ធ្វើការងារតាមចំនួនដែលគេតំណត់ឲ្យមិនហើយ។ ពួកខ្មែរក្រហមបាននាំយកគាត់ទៅដាក់ក្នុងមន្ទីរសន្តិសុខកូនង៉ែត (ស្ថិតក្នុងភូមិព្រែកក្តី ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ) ដោយចោទគាត់ថាជាក្បាលយួនខ្លួនខ្មែរ និងជាគិញកាហ្សេបេ។ បងប្រុសរបស់អ្នកដាក់ពាក្យសុំត្រូវបានគេធ្វើទារុណកម្ម ដើម្បីឲ្យគាត់ឆ្លើយសារភាពចំពោះការចោទប្រកាន់ទាំងនេះ។ ក្នុងពេលនោះប្រធានមន្ទីរសន្តិសុខមិនអនុញ្ញាតឲ្យម្តាយរបស់គាត់ទៅជួបសួរសុខទុក្ខគាត់ទេ។ លុះដល់ឆ្នាំ១៩៧៨ ក្រោយពីជាប់ឃុំឃាំងប្រហែលបីខែ ឡុង ពាន ត្រូវបានពួកខ្មែរក្រហមចងស្លាបសេក ហើយចងមុខនាំយកទៅទីតាំងសម្លាប់កោះស្លាដែលស្ថិតក្នុងឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ។ មួយខែក្រោយមក អ្នកដាក់ពាក្យសុំបានឮថា ខ្មែរក្រហមបានសម្លាប់ឡុង ពាន ហើយ ពីព្រោះគាត់មិនព្រមសារភាពថាគាត់ជាគិញកាហ្សេបេ[85]។

(១៤) សមាជិកគ្រួសាររបស់អ្នកដាក់ពាក្យសុំ ហឿង សុវណ្ណា (13-VSS-00389) ត្រូវបានកំណត់គោលដៅជាខ្មាំងរបស់របបខ្មែរក្រហម។ នៅចុងឆ្នាំ១៩៧៦ បងថ្លៃប្រុសរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ តោក កក់ ត្រូវពួកខ្មែរក្រហមចាប់ដាក់គុក និងសម្លាប់នៅមន្ទីរសន្តិសុខដំណាក់វទេះ ដោយចោទថាជាភ្នាក់ងារសេអ៊ីអា។ នៅដើមឆ្នាំ១៩៧៧ បងប្រុសបង្កើតរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ តៅ ថុនសម្បត្តិ ដែលជាអតីតនិស្សិតឆ្នាំទី២នៃសាកលវិទ្យា

[85] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/281 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡុង ផាង ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ ERN 00556746-47។

ល័យបាត់ដំបងក្នុងឆ្នាំ១៩៧៥ ត្រូវបានពួកខ្មែរក្រហមចាប់ធ្វើទារុណកម្ម ដោយចោទថា គាត់ជាអ្នកចេះដឹងរៀនបានខ្ពស់។ ឪពុកបង្កើតរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ តៅ ហឿង ដំបូងត្រូវបានគេចាត់ឲ្យចាំចំការ តែក្រោយមកត្រូវបានចាប់ខ្លួន និងធ្វើទារុណកម្ម ដោយចោទថាគាត់ជាភ្នាក់ងារសេអ៊ីអា ដែលបានបណ្ដាលឲ្យគាត់ស្លាប់១៨ថ្ងៃក្រោយមក[86]។

(១៥) គ្រួសាររបស់អ្នកពាក្យសុំ ឆាយ យ៉ាន (15-VSS-00022) ក៏ត្រូវបានអ្នកដឹកនាំខ្មែរក្រហមកំណត់ជាគោលដៅដែរ ដោយសារពួកគេមានការជាប់ពាក់ព័ន្ធជាមួយសង្គមចាស់ និងជាវណ្ណៈដែលពួកខ្មែរក្រហមមិនពេញចិត្ត។ នៅក្នុងខែតុលា ឆ្នាំ១៩៧៦ ប្អូនប្រុសបង្កើតរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ ឆាយ សាលី ប្រពន្ធ និងកូនរបស់គាត់ត្រូវបានកម្មាភិបាលខ្មែរក្រហមសម្លាប់នៅក្នុងឃុំព្រៃក្មេង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្រោយពីពួកខ្មែរក្រហមបានរកឃើញរូបថតដែលបង្ហាញថា ប្អូនប្រុសរបស់គាត់ គឺជាគ្រូពេទ្យ។ ក្រោយពីនោះមក នៅពាក់កណ្ដាលឆ្នាំ១៩៧៧ ប្អូនប្រុសគាត់ម្នាក់ទៀត ឈ្មោះ ឆាយ ភឹម ត្រូវបានពួកខ្មែរក្រហមយកទៅសម្លាប់នៅក្នុងឃុំតាំងក្រូច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដោយសារគាត់ធ្លាប់ធ្វើជាគ្រូបង្រៀនក្នុងសម័យលន់ នល់[87]។

35. ម្ចាស់បណ្ដឹងឧទ្ធរណ៍ដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ "ង" បានផ្ដល់រាល់ព័ត៌មានគ្រប់គ្រាន់ទាំងអស់ ដើម្បីបង្ហាញថា ពួកគេជាសមាជិកនៅក្នុងក្រុម ឬសហគមន៍គោលដៅជាក់លាក់មួយ ឬច្រើន

---

[86] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1516 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ហឿង សុវណ្ណា ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ ERN 01133092។

[87] *សូមមើល*សំណុំរឿង ០០៤/២ ឯកសារ D5/1685 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឆាយ យ៉ាន ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥ ERN 01156354-55។

ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ។ ផ្អែកលើមូលដ្ឋាននេះ អង្គបុរេជំនុំជម្រះគួរបដិសេធដីកាដែលរងការជំទាស់ ហើយទទួលយកម្ចាស់បណ្តឹងឧទ្ធរណ៍ទាំងនេះជាដើមបណ្តឹងរដ្ឋប្បវេណី។

**ខ. មូលដ្ឋានទី២នៃបណ្តឹងឧទ្ធរណ៍៖ ការបំបែកសំណុំរឿង ០០៤/២ ពីសំណុំរឿង ០០៤ មិនគួរប្រើប្រាស់ជាកត្តាកំណត់ពីភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី**

36. សហចៅក្រមស៊ើបអង្កេតអន្តរជាតិភ័ន្តច្រឡំថា ដីកាបំបែកសំណុំរឿង ០០៤/២ ដាក់កម្រិតលើសមត្ថភាពរបស់ខ្លួន ក្នុងការពិចារណាលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤ មុនការបំបែករាប់បញ្ចូលទាំងឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តនៅក្រៅភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ដែលតាមរយៈនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់ម្ចាស់បណ្តឹងឧទ្ធរណ៍។

37. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានចេញ*ដីកាសម្រេចបំបែក អោ អាន* ពីសំណុំរឿង ០០៤ និងបង្កើតសំណុំរឿង ០០៤/២[88]។ នៅក្នុងដីកាបំបែកសំណុំរឿងរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតបានអះអាងថា ពួកគេ “ជឿជាក់ថា ការបំបែកសំណុំរឿងនេះនឹងចៀសវាងមិនឲ្យមានការពន្យារពេលសំណុំរឿង អោ អាន ឲ្យយូរហួសឡើយ *ហើយក៏មិនប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយឡើយ* ខណៈដែលអង្គហេតុដែលនៅសេសសល់ទាំងអស់នៅក្នុងសំណុំរឿង ០០៤ នៅ

[88] សំណុំរឿង ០០៤/២ ឯកសារ D334/1 ដីកាសម្រេចបំបែក អោ អាន ពីសំណុំរឿង ០០៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ [តទៅនេះហៅថា ដីកាសម្រេចបំបែកសំណុំរឿង ០០៤/២]។

បន្តស៊ើបសួរ"[89]។ ក៏ប៉ុន្តែ ដូចដីកាដែលរងការជំទាស់ជាភ័ស្តុតាងស្រាប់ វិសាលភាពសម្រាប់អាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/២ បន្ទាប់ពីការចេញដីកាសម្រេចបំបែកសំណុំរឿង ត្រូវបានកម្រិតត្រឹមតែ "អ្នកដាក់ពាក្យសុំដែលទទួលរងព្យសនកម្មនៅក្នុងភូមិភាគកណ្តាល ចាប់តាំងពីពេលប្រហែលជានៅចុងឆ្នាំ១៩៧៦ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[.]" ប៉ុណ្ណោះ[90]។ ធ្វើបែបនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកាត់បន្ថយយ៉ាងច្រើននូវវិសាលភាពពេលវេលា និងភូមិសាស្ត្រ ដែលត្រូវបានគ្របដណ្តប់ដោយឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងដើមនៃសំណុំរឿង ០០៤ ដោយរារាំងប្រកបដោយប្រសិទ្ធភាពដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅក្នុងសំណុំរឿងមុន មិនឲ្យពួកគេបន្តចូលរួមនៅក្នុងដំណើរការនីតិវិធី។

38. ការបកស្រាយរបស់សហចៅក្រមអន្តរជាតិអំពីផលប៉ះពាល់នៃដីកាសម្រេចបំបែកសំណុំរឿងទៅលើវិសាលភាពនៃបទឧក្រិដ្ឋពាក់ព័ន្ធដែលត្រូវបានចោទប្រកាន់ គឺវាផ្ទុយពីសិទ្ធិរបស់ជនរងគ្រោះដែលតម្រូវឲ្យតុលាការមានទស្សនៈទូលំទូលាយចំពោះភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ច្បាស់ថា យោងតាមគោលការណ៍ជាសារវន្តនៃនីតិវិធីនៅចំពោះមុខ អ.វ.ត.ក វិធានផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍ និងសិទ្ធិ

---

[89] ដីកាសម្រេចបំបែកសំណុំរឿង ០០៤/២ កថាខណ្ឌ ៤ (បន្ថែមពាក្យសង្កត់ន័យ)។

[90] សំណុំរឿង ០០៤/២ ឯកសារ D362 ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៣៧។

របស់ជនរងគ្រោះ[91]។ ជាពិសេសសម្រាប់គោលដៅនៃការបង្រួបបង្រួមជាតិរបស់ អ.វ.ត.ក ចៅក្រម និងអង្គជំនុំជម្រះនៅអ.វ.ត.ក ត្រូវតែយកចិត្តទុកដាក់ជាពិសេស និងធានាថា មានការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះនៃអំពើឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្ត”[92]។ ដីកាដែលរងការជំទាស់ប្រព្រឹត្តផ្ទុយពីគោលដៅនេះយ៉ាងប្រចក្ស តាមរយៈការកម្រិតវិសាលភាពនៃការទទួលយកដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/២។

39. អ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺសហចៅក្រមស៊ើបអង្កេតពុំបានធ្វើការចង្អុលបង្ហាញជាមុនថា ដីកាសម្រេចបំបែកសំណុំរឿង នឹងមានផលប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី កុំថាឡើយតែក្នុងវិសាលភាពទូលំទូលាយបែបនេះ។ ជាបញ្ហាចម្បង សហចៅក្រមស៊ើបអង្កេតបានខកខានក្នុងការពិគ្រោះយោបល់ជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ឬមេធាវីតំណាងពួកគេ ជាមុន អំពីដីកាសម្រេចបំបែកសំណុំរឿង ទោះបីជាវិធាន៦៦ *ស្ទួន*នៃវិធានផ្ទៃក្នុងតម្រូវឲ្យផ្តល់ឱកាសដល់ភាគីនានាក្នុងការធ្វើសំណើលើបញ្ហានេះក៏ដោយ[93]។ ដីកសម្រេចបំបែកសំណុំរឿងក៏មិនបញ្ចូលសេចក្តីសម្រេចដែលមានសម្អាងហេតុណាមួយរបស់សហចៅក្រមស៊ើប

[91] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦១។

[92] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៥។ *សូមមើលផងដែរ* ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបឋម *ដែលបានលើកឡើងខាងដើម*។

[93] វិធាន៦៦ *ស្ទួន* (២) នៃវិធានផ្ទៃក្នុង (“មុនពេលកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេត ត្រូវជូនដំណឹងអំពីព័ត៌មានលម្អិតស្ដីពីគោលបំណងនៃការកាត់បន្ថយ ទៅសហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដទៃទៀត។ ភាគីទាំងអស់ត្រូវដាក់សារណាក្នុងរយៈពេល១៥ ថ្ងៃ យ៉ាងយូរ។

អង្កេត ពាក់ព័ន្ធនឹងផលប៉ះពាល់ដែលអាចកើតមានរបស់ដីកាសម្រេចនេះទៅលើដើមបណ្ដឹងរដ្ឋប្បវេណី ឬព័ត៌មានណាមួយទាក់ទងនឹងគោលជំហររបស់សហចៅក្រមស៊ើបអង្កេតលើវិសាលភាពនីមួយៗនៃសំណុំរឿង ០០៤, ០០៤/១ និង០០៤/២ ជាធាតុផ្សំដែលត្រូវបានតម្រូវដោយវិធានផ្ទៃក្នុងផងដែរ[94]។ ចំពោះការងាររដ្ឋបាល ផ្នែកគាំពារជនរងគ្រោះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តកត់ត្រាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ជាអ្នកដាក់ពាក្យសុំក្នុងសំណុំរឿង ០០៤ ដោយមិនបានធ្វើការបែងចែកតាមសំណុំរឿងដែលត្រូវបានបំបែកឡើយ។ ប្រាកដណាស់ ទាល់តែដល់ពេលចេញដីកាដែលរងការជំទាស់ ទើបផលប៉ះពាល់នៃដីកាសម្រេចបំបែកសំណុំរឿងបានចេញជារូបរាងជាក់ស្ដែង នោះគឺការកំណត់ពេលវេលាដោយឡែកសម្រាប់ការដាក់ពាក្យសុំ បន្ទាប់ពីការបិទបញ្ចប់ការស៊ើបអង្កេត[95]។

---

[94] វិធាន៦៦ *ស្ទួន* (៣) នៃវិធានផ្ទៃក្នុង ("សហចៅក្រមស៊ើបអង្កេត ត្រូវកំណត់អំពីអានុភាពនៃសេចក្ដីសម្រេចដែលបានធ្វើឡើងអនុលោមតាមអនុវិធាន(១) ខាងលើ ទៅលើឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងទៅលើសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរ")។

[95] ដីកាសម្រេចបំបែកសំណុំរឿងបានបន្តបង្កើតនូវវិសមធម៌ផ្នែកនីតិវិធីក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដោយបានកំណត់ពេលវេលាដោយឡែកសម្រាប់ការចូលរួមនៅក្នុងដំណើរការនីតិវិធីសំណុំរឿង ០០៤ បីផ្សេងគ្នា។ សហចៅក្រមស៊ើបអង្កេតបានបិទបញ្ចប់ការស៊ើបអង្កេត និងបានបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងអ៊ឹម ចែម ពីសំណុំរឿង ០០៤ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦។ សំណុំរឿង ០០៤/១ ឯកសារ D286/7 ដីកាសម្រេចបំបែក អ៊ឹម ចែម ពីសំណុំរឿង ០០៤ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ (តទៅនេះហៅថា "ដីកាសម្រេចបំបែកសំណុំរឿង ០០៤/១")។ ពេលវេលាកំណត់សម្រាប់ការចូលរួមរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង ០០៤/១ គឺថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៦។ សូមមើលវិធាន២៣ *ស្ទួន*(២) នៃវិធានផ្ទៃក្នុង (ដែលចែងថា ជនរងគ្រោះត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ យ៉ាងយូរ១៥ ថ្ងៃ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ភាគីទាំងអស់អំពីការបញ្ចប់កិច្ចស៊ើបសួរ)។ នៅក្នុងករណី អោ អាន (សំណុំរឿង ០០៤/២ សហចៅក្រមស៊ើបអង្កេតបានបំបែកដំណើរការនីតិវិធី និងពីដំបូង បានបិទបញ្ចប់ការស៊ើបអង្កេតលើគាត់នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។ សំណុំរឿង ០០៤ ឯកសារ D334/1 ដីកាសម្រេចបំបែក អោ អាន ពីសំណុំរឿង ០០៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ [តទៅនេះហៅថា "ដីកាសម្រេចបំបែកសំណុំរឿង ០០៤/២"]។ ពេលវេលាកណត់សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងក្នុងសំណុំរឿង ០០៤/២ គឺថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតមិនបានបញ្ចប់

40. ការបដិសេធ*ជារួម*របស់ដីកាដែលរងការជំទាស់ចំពោះអ្នកដាក់ពាក្យសុំដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាដើមបណ្តឹងរដ្ឋប្បវេណី (លើកលែងតែការបំបែកសំណុំរឿង ០០៤/២) នៅក្នុងសំណុំក្នុងសំណុំរឿង ០០៤ ជំទាស់ទៅនឹងដីកាសម្រេចបំបែកសំណុំរឿងផ្ទាល់ដែលប្រកាសថា ការចេញដីកានេះនឹងមិនប៉ះពាល់ដល់សិទ្ធិរបស់ភាគីនានា[96]។ តាមពិត ដីកាសម្រេចបំបែកសំណុំរឿងនេះបានក្លាយជាកត្តាកំណត់លើភាពអាចទទួលបាននៃដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់អ្នកដាក់ពាក្យសុំយ៉ាងច្រើន រួមទាំងម្ចាស់បណ្តឹងឧទ្ធរណ៍។ ជាលទ្ធផលនៃដីកាសម្រេចបំបែកសំណុំរឿងនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្ហាញការមិនយកចិត្តទុកដាក់ចំពោះការចោទប្រកាន់យ៉ាងទូលំទូលាយនៅក្នុងសំណុំរឿង ០០៤ ពីមុន រាប់បញ្ចូលទាំងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងភូមិភាគពាយ័ព្យ និងភូមិភាគនិរតី និងបានពិនិត្យតែលើការចោទប្រកាន់ទាំងឡាយដែលគាត់ពិចារណាថាស្ថិតក្នុងរង្វង់ព្រំដែននៃការទទួលខុសត្រូវដែលត្រូវបានកំហិតថ្មីក្នុងសំណុំរឿង ០០៤/២ ប៉ុណ្ណោះ[97]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនគួរត្រូវបានគេបដិសេធមិនឲ្យចូលរួមសមស្របនៅក្នុងដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២ ផ្អែកលើមូលដ្ឋាននេះឡើយ។ ការសម្រេចផ្ទុយពីនេះ គឺមានន័យថា អនុញ្ញាតឲ្យមានការអនុវត្តនីតិវិធីជាធម្មតា ក្នុងគោលបំណងពន្លឿនកិច្ច

---

ការស៊ើបអង្កេតលើសំណុំរឿង ០០៤ ប្រឆាំងនឹងជនត្រូវចោទម្នាក់ទៀត គឺយឹម ទិត ឡើយរហូតដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០១៧ ដែលបានអនុញ្ញាតឲ្យជនរងគ្រោះដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងនេះរហូតដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧។

[96] ដីកាសម្រេចបំបែកសំណុំរឿង ០០៤/២ កថាខណ្ឌ ៥។

[97] ដីកាដែលរងការជំទាស់ កថាខណ្ឌ ៣៧-៣៨ (ដាក់កម្រិតលើភាពអាចទទួលយកបានត្រឹមគោលនយោបាយចំនួន០៤ ដែលត្រូវបានប្រព្រឹត្តនៅក្នុងភូមិភាគភូមិភាគកណ្តាល (ឧត្តរចាស់) ដែលក្នុងនោះ អោ អានត្រូវគេចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវ)។

ដំណើរការនីតិវិធី ដកហូតសិទ្ធិជនរងគ្រោះក្នុងការចូលរួមប្រកបដោយអត្ថន័យក្នុងកិច្ចដំណើរការនីតិវិធី ដែលពាក់ព័ន្ធដោយផ្ទាល់នឹងឧក្រិដ្ឋកម្ម និងគោលនយោបាយដែលត្រូវបានចោទប្រកាន់ដែលបានធ្វើឱ្យពួកគេទទួលរងនូវព្យសនកម្មយ៉ាងធំធេង។

41. ចំពោះអ្វីដែលបានលើកឡើងខាងលើ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើអង្គបុរេជំនុំជម្រះសម្រេចថា ដីកាសម្រេចបំបែកសំណុំរឿងបានបង្កការប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដោយគ្មានការអនុញ្ញាត និងបដិសេធសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាន។ ដូចពន្យល់លម្អិតនៅក្នុងឧបសម្ព័ន្ធ ខ, គ និងឃ ម្ចាស់បណ្តឹងឧទ្ធរណ៍ម្នាក់ៗដែលមានឈ្មោះនៅក្នុងបញ្ជី សុទ្ធតែបានទទួលរងព្យសនកម្មដែលជាផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងវិសាលភាពនៃសំណុំរឿង ០០៤ មុនពេលបំបែក។

**គ. មូលដ្ឋានទី៣នៃបណ្តឹងឧទ្ធរណ៍៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសលើអង្គច្បាប់ ដោយបានខកខានមិនបានផ្តល់សេចក្តីសម្រេចមានសម្អាងហេតុសម្រាប់ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

42. អង្គបុរេជំនុំជម្រះបានដាស់តឿនសហចៅក្រមស៊ើបអង្កេតថា ពួកគេត្រូវតែចេញសេចក្តីសម្រេចដែលមានសម្អាងហេតុលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ដើម្បីគោរពគោលការណ៍ជាសារវ័ន្តនៃភាពស្របច្បាប់ រាប់បញ្ចូលទាំងតម្លាភាព និងសច្ចភាពផ្លូវច្បាប់[98]។ ខណៈដែល

[98] សំណុំរឿង ០០២ ឯកសារ D411/3/6 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧-៣៨។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានសម្រេចថា សិទ្ធិទទួលសេចក្តីសម្រេចមានសម្អាងហេតុ គឺជាធាតុផ្សំនៃសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងថា មានតែឈរមូលដ្ឋាននៃសេចក្តីសម្រេចមានសម្អាងហេតុប៉ុណ្ណោះទើបការពិនិត្យសើរើអាចធ្វើបានសមស្របនៅសាលា

សហចៅក្រមស៊ើបអង្កេតមិនត្រូវរៀបរាប់លម្អិតគ្រប់កត្តានៅក្នុងដំណើរការធ្វើសេចក្តីសម្រេច យ៉ាងហោចណាស់ក៏សហចៅក្រមស៊ើបអង្កេតត្រូវតែ "បង្ហាញទាំងស្រុងនូវឯកសារសម្ភារៈ ដែលចៅក្រមបានយកមកពិចារណានៅពេលចេញសេចក្តីសម្រេច"[99]។ ជាពិសេស សិទ្ធិប្តឹងឧទ្ធរណ៍ដែលមានចែងក្នុងវិធានផ្ទៃក្នុង នឹងគ្មានន័យ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលព័ត៌មានអំពីសម្អាងហេតុនៃសេចក្តីសម្រេចដែលពួកគេប្តឹងឧទ្ធរណ៍នោះ។ ស្រដៀងគ្នានេះដែរ អង្គបុរេជំនុំជម្រះមិនអាចធ្វើការពិនិត្យឡើងវិញលើការបដិសេធបានត្រឹមត្រូវ និងមានប្រសិទ្ធភាពបានទេ បើសិនជាគ្មានការយល់ដឹងគ្រប់គ្រាន់អំពីសម្អាងហេតុជាមូលដ្ឋានទេនោះ[100]។

---

ឧទ្ធរណ៍។ *សូមមើល* រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង Momir Nikolic* សាលដីកាផ្តន្ទាទោសក្នុងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០៦ សំណុំរឿងលេខ IT-02-60/1-A កថាខណ្ឌ ៩៦។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានសម្រេចថា "យ៉ាងហោចណាស់ អង្គជំនុំជម្រះសាលាដំបូងត្រូវផ្តល់សម្អាងហេតុ ដើម្បីគាំទ្រសេចក្តីសម្រេចរបស់ខ្លួន ទាក់ទងនឹងការពិចារណាលើអង្គសេចក្តីដែលពាក់ព័ន្ធនឹងការសម្រេចរបស់ខ្លួន"។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង Milutinovic និងអ្នកដទៃទៀត* សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ហំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលអនុញ្ញាតឲ្យដោះលែង Nebojsa Pavkovic ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៥, សំណុំរឿងលេខ IT-05-87-AR65.1 កថាខណ្ឌ ១១។ *សូមមើលផងដែរ* រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង Lubanga* ឯកសារ ICC-01/04-01/06-774 សាលដីកាបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ១ ដែលមានចំណងជើងថា "សេចក្តីសម្រេចលើកទី២លើសំណើរបស់អយ្យការ និងវិសោធនកម្មសំណើសុំធ្វើការកែតម្រូវស្របតាមវិធាន៨១" ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣០៖ "មានតែឈរមូលដ្ឋាននៃសេចក្តីសម្រេចមានសម្អាងហេតុប៉ុណ្ណោះ ទើបអាចមានការពិនិត្យសើរើសមស្របដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍"។

[99] សំណុំរឿង ០០២ ឯកសារ D411/3/6 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៩។

[100] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៨។

43. នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះរកឃើញថា ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេត មិនគោរពតាមលក្ខខណ្ឌតម្រូវសម្រាប់សេចក្តីសម្រេចដែលមានសម្អាងហេតុ[101]។ នៅក្នុងសំណុំរឿងនោះ សហចៅក្រមស៊ើបអង្កេតមានកំហុស ដោយបានបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ផ្អែកលើមូលហេតុជាទូទៅដូចជា "ទំនាក់ទំនងហេតុ និងផលចាំបាច់រវាងព្យសនកម្មដែលបានលើកឡើង និងអង្គហេតុទាំងឡាយដែលស្ថិតនៅក្រោមការស៊ើបអង្កេត មិនត្រូវបានបង្ហាញ"[102]។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា តារាងឧបសម្ព័ន្ធដែលមានសម្អាងហេតុបន្ថែមរបស់សហចៅក្រមស៊ើបអង្កេតសម្រាប់អ្នកដាក់ពាក្យសុំម្នាក់ មានយ៉ាងច្រើនបំផុតពីរឃ្លា ដែលឃ្លានីមួយៗមានពី០៥ ទៅ១៥ពាក្យ ហើយខ្លឹមសារសម្រាប់ការច្រានចោលអ្នកដាក់ពាក្យសុំម្នាក់ៗ មិនមានភាពជាក់លាក់ចំពោះអ្នកដាក់ពាក្យសុំម្នាក់ៗទេ[103]។

44. ស្រដៀងគ្នានេះដែរ ដីកាដែលរងការជំទាស់ ខកខានមិនបានគោរពតាមបទដ្ឋានអប្បបរមា ដែលត្រូវបានកំណត់ដោយអង្គបុរេជំនុំជម្រះសម្រាប់សេចក្តីសម្រេចដែលមានសម្អាងហេតុ។ កិច្ចស៊ើបសួរ

---

[101] សំណុំរឿង ០០២ ឯកសារ D411/3/6 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧។

[102] សំណុំរឿង ០០២ ឯកសារ D411/3/6 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧។

[103] សំណុំរឿង ០០២ ឯកសារ D411/3/6 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧។

របស់សហចៅក្រមស៊ើបអង្កេតជាតិ បានបញ្ចប់នៅត្រឹមកម្រិតផ្នែកយុត្តាធិការ ដោយពុំបានធ្វើការវាយតម្លៃលើលក្ខណសម្បត្តិជាមូលដ្ឋាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែបានច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងច្រើនលើសលប់*ជារួម*ដោយពុំបានធ្វើការពិចារណាត្រឹមត្រូវលើពាក្យសុំនីមួយៗ។ ដូចក្នុងសំណុំរឿង ០០២ សម្អាងហេតុ ឬការខ្វះសម្អាងហេតុ សម្រាប់ការបដិសេធពាក្យសុំ មានកម្រិតត្រឹមតែពាក្យពេចន៍ពីរបីឃ្លាខ្លីៗ ដែលគេអាចយកមកប្រើប្រាស់ឡើងវិញបានច្រើនដង។ បើនិយាយឲ្យជាក់លាក់ ដីកាដែលរងការចោទប្រកាន់បដិសេធម្ចាស់បណ្តឹងឧទ្ធរណ៍ជិតពាក់កណ្តាល ផ្អែកលើមូលហេតុថា ម្ចាស់បណ្តឹងឧទ្ធរណ៍៖ (ក) អង្គហេតុដែលបានពិពណ៌នាស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿងនេះ ឬ (ខ) មិនត្រូវបានបង្ហាញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលរងព្យសនកម្ម ជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើនដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ[104]។ នៅក្នុងករណីមួយទៀត ដីកាដែលរងការជំទាស់ សង្ខេបឡើងវិញពីអង្គហេតុ ប៉ុន្តែពិតជាបញ្ជាក់ពីមូលហេតុដែលបណ្តាលឲ្យសហចៅក្រមអន្តរជាតិច្រានចោលនូវការដាក់ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី (មូលដ្ឋានទី៨)។ ដីកាដែលរងការជំទាស់មិនបានផ្តល់ការបញ្ជាក់បន្ថែមណាមួយចំពោះភាពខុសគ្នារវាងមូលហេតុទាំងពីរនៃការច្រានចោលនេះឡើយ។ ការខ្វះខាតភាពជាក់លាក់ពាក់ព័ន្ធ

[104] សំណុំរឿង ០០២ ឯកសារ D362.2 ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលស្គាល់ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៨។

នឹងសម្អាងហេតុសម្រាប់ការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ មិនអនុញ្ញាតឲ្យម្ចាស់បណ្តឹងឧទ្ធរណ៍អាចអនុវត្តសិទ្ធិប្តឹងឧទ្ធរណ៍របស់ខ្លួនបានភ្លាមៗឡើយ។

45. ដូចបានពន្យល់លម្អិតក្នុងឧបសម្ព័ន្ធ ឆ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើអង្គបុរេជំនុំជម្រះច្រានចោលដីកាដែលរងការជំទាស់ ក្នុងគ្រប់ករណីដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានរកឃើញមិនអាចទទួលយកបានដោយសារពួកគេ "ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង" (លេខកូដ ១) ឬក្នុងករណីដែល "មិនត្រូវបានបង្ហាញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលរងព្យសនកម្ម ជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើនដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ (លេខកូដ ៣) ផ្អែកលើមូលដ្ឋានថា ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះមិនត្រូវធ្វើឡើងដោយគ្មានដីកាដែលមានសម្អាងហេតុគ្រប់គ្រាន់។

**ឃ. មូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍៖ សហចៅក្រមស៊ើបអង្កេតមានកំហុសលើអង្គហេតុ ដោយបានច្រានចោលម្ចាស់បណ្តឹងឧទ្ធរណ៍ចំពោះការខកខានមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ស្របតាមលក្ខខណ្ឌតម្រូវដែលបានចែងក្នុងវិធាន២៣ ស្ទួន (១) និង (៤) នៃវិធានផ្ទៃក្នុង និងមូលដ្ឋានដែលពាក់ព័ន្ធ។**

46. វិធាន២៣ ស្ទួន (១) និង (៤) នៃវិធានផ្ទៃក្នុង និងមាត្រា៣.២ នៃសេចក្តីណែនាំអនុវត្តន៍ ចែងថា គ្រប់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ត្រូវមានព័ត៌មានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យពិនិត្យបញ្ជាក់អំពីភាពសមស្របរបស់ពាក្យបណ្តឹងជាមួយវិធានផ្ទៃក្នុងនេះ[105]។ ជាពិសេស ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវផ្តល់ព័ត៌មានលម្អិតអំពីអត្តសញ្ញាណ និងឋានៈជាជន

---

[105] វិធាន២៣ *ស្ទួន* (១) និង(៤) នៃវិធានផ្ទៃក្នុង។

រងគ្រោះ ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងភស្តុតាងបញ្ជាក់អំពីពន្យសនកម្មដែលទទួលរង ឬព័ត៌មាន “បង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជនដែលត្រូវចោទប្រកាន់”[106]។ ព័ត៌មានត្រូវចាត់ទុកថាគ្រប់គ្រាន់ នៅពេលដែលព័ត៌មាននោះអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតជឿជាក់ថា អង្គហេតុដែលបានអះអាង អាចជាការពិត[107]។

47. ដូចដែលបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ វិធាន២៣ *ស្ទួន* នៃវិធានផ្ទៃក្នុងមានកម្មវត្ថុ និងគោលបំណងកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មិនមែនដាក់កំហិត ឬកម្រិតលើទស្សនៈនៃបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ[108]។ ការដាក់វិធាន២៣ *ស្ទួន* នៅក្នុងអនុជំពូកស្ដីពីបទប្បញ្ញត្តិទូទៅនៃជំពូកស្ដីពីនីតិវិធីនៃវិធានផ្ទៃក្នុង គួសបញ្ជាក់ថា វិធាននេះត្រូវតែបកស្រាយស្របគ្នាជាមួយវិធាន២១ ដែលកំណត់អំពីករណីយកិច្ចជាសារវន្ត ក្នុងការការពារប្រយោជន៍របស់ជនរងគ្រោះ និងធានាអំពីសច្ចភាពផ្លូវច្បាប់ និងតម្លាភាព[109]។

---

[106] វិធាន២៣ *ស្ទួន* (៤) នៃវិធានផ្ទៃក្នុង។

[107] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៩៥។

[108] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦២។

[109] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦១។ *សូមមើលផងដែរ* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបឋម *ដែលបានលើកឡើងខាងដើម*។

48. សហចៅក្រមស៊ើបអង្កេតត្រូវតែសម្រេចថា តើមានមូលដ្ឋានដែលគួរឲ្យជឿជាក់បាន*ជាបឋម* ដែលចង្អុលបង្ហាញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពិតជាបានទទួលរងព្យសនកម្ម ដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងអង្គហេតុដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរផ្អែកលើមូលដ្ឋាននៃធាតុផ្សំនៅក្នុងសំណុំរឿងនោះដែរឬអត់។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា ដោយសារកម្រិតធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានដោះស្រាយនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា “វាជាការមិនត្រឹមត្រូវ ប្រសិនបើយើងពិនិត្យមើលការខូចខាតដែលបង្កអំពើសាហាវឃោរឃៅជាទ្រង់ទ្រាយធំ តែទៅលើមូលដ្ឋានជាបុគ្គល ព្រោះការខូចខាតនេះគ្របដណ្តប់ទៅលើផ្នែកជាបុគ្គលនានា”[110]។ ដោយទទួលស្គាល់ថា អំពើសាហាវឃោរឃៅ ដែលជាផលវិបាកនៃការអនុវត្តគោលនយោបាយជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំ ហើយដែលការអនុវត្តផ្តោតទៅលើសហគមន៍ទាំងមូល ក៏ដូចជាទៅលើក្រុមជាក់លាក់នានា ព្រមទាំងបុគ្គលនៅក្នុងសហគមន៍នោះផង សហចៅក្រមស៊ើបអង្កេតបានសម្រេចថា “ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គល ត្រូវតែបានពិនិត្យមើលក្នុងស្ថានភាពពិសេសនៃជម្លោះ”[111]។

---

[110] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧០។

[111] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧០។

49. នៅក្នុងដីកាដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលស្គាល់ពីកត្តាចំនួន៣ ដែលដោះបន្ទុកភស្តុតាងនៃព្យសនកម្មដែលចាំបាច់ថែមទៀតសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គល។ កត្តាទាំងបីនោះ គឺ៖

ក) ពេលវេលាកន្លងផុតទៅយូរ និងផលប៉ះពាល់ដែលបញ្ហានេះអាចមានមកលើលទ្ធភាពរបស់អ្នកដាក់ពាក្យសុំ ក្នុងការផ្តល់ឯកសារភស្តុតាងពាក់ព័ន្ធនឹងព្យសនកម្មដែលខ្លួនទទួលរង ដូចជា ឯកសារពេទ្យក្នុងករណីដែលការចោទប្រកាន់អំពីព្យសនកម្មខាងរាងកាយ។

ខ) ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ មានបញ្ហាសមត្ថភាពក្នុងការបង្ហាញ ក្នុងការឆ្លើយតប ឬធ្វើកំណត់ហេតុឱ្យបានស៊ីជម្រៅ និងត្រឹមត្រូវអំពីផលប៉ះពាល់ ដែលស្ថានភាពនៅសម័យកម្ពុជាប្រជាធិបតេយ្យមានមកលើសុខភាពផ្លូវចិត្តរបស់ប្រជាជន។

គ) ការជម្លៀស ការប្តូរទីកន្លែង និងការផ្លាស់ទីលំនៅរបស់ប្រជាជនទៅតាមតំបន់ផ្សេងៗ និងផលប៉ះពាល់ដែលបញ្ហានេះមានមកលើលទ្ធភាពរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការផ្តល់ភស្តុតាងបញ្ជាក់អំពីកម្មសិទ្ធិក្នុងករណីមានការចោទប្រកាន់អំពីការបាត់បង់ទ្រព្យសម្បត្តិ និងលទ្ធភាពក្នុងការផ្តល់ភស្តុតាងបញ្ជាក់អំពីប្រាក់ចំណូលក្នុងករណីមានការចោទប្រកាន់អំពីការបាត់បង់ប្រាក់ចំណូល[112]។

50. កាលពីមុន សហចៅក្រមស៊ើបអង្កេតបានអនុវត្តនូវវិធីសាស្ត្រមួយដែលមានការបត់បែន ទាក់ទិននឹងលក្ខខណ្ឌតម្រូវសម្រាប់ការបញ្ជាក់ភស្តុតាងពីអត្តសញ្ញាណ[113]។ នៅក្នុងដីកាដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលស្គាល់ថា មានការលំបាកសម្រាប់ជនរងគ្រោះជា

---

[112] ដីកាដែលរងការជំទាស់ កថាខណ្ឌ ៤១។

[113] សំណុំរឿង ០០២ ឯកសារ D404 ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអសយដ្ឋាននៅក្រៅព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១០-១១។

ច្រើន ក្នុងការផ្តល់ឯកសារភស្តុតាង ដើម្បីគាំទ្រចំពោះការអះអាងរបស់ពួកគេ និងបានបញ្ជាក់ពីគោលជំហររបស់អង្គបុរេជំនុំជម្រះថា "ឯកសារដែលចេញជាទម្រង់ ឬឯកសារផ្សេងទៀតពីចាស់ទុំក្នុងភូមិ ឬមេឃុំ គឺជាព័ត៌មានគ្រប់គ្រាន់ហើយក្នុងការបញ្ជាក់អត្តសញ្ញារបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ យើង Michael Bohlander ក៏ទទួលស្គាល់ដែរថា ក្នុងករណីគ្មានអត្តសញ្ញាណប័ណ្ណ ឬស្នាមក្រយៅដៃ គឺជាព័ត៌មានគ្រប់គ្រាន់ហើយ ប្រសិនបើអ្នកដាក់ពាក្យសុំអាចត្រូវស្គាល់អត្តសញ្ញាណបានតាមរយៈព័ត៌មានដែលមាននៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះ"[114]។

51. ដីកាដែលរងការជំទាស់បានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្រោមមូលហេតុចំនួនបួន ទាក់ទងនឹងភាពគ្រប់គ្រាន់ ឬគុណភាពនៃព័ត៌មានដែលបានផ្តល់នៅក្នុងពាក្យសុំ និងក្រោមមូលហេតុមួយលើមូលដ្ឋានថា អ្នកដាក់ពាក្យសុំ ពុំមានលក្ខណសម្បត្តិគ្រាន់គ្រាន់ ដើម្បីទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារគាត់ជាអតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។

52. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ក្នុងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះដែលបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ជ(១) និងឧបសម្ព័ន្ធ ជ(២) ដោយសារមូលហេតុដែលបានបញ្ជាក់នៅក្នុងដីកានោះ និងសូមស្នើដល់អង្គបុរេជំនុំជម្រះច្រានចោលសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើភាពមិនអាចទទួលយកបាន និងផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដល់ជនរងគ្រោះទាំងនេះ។

---

[114] ដីកាដែលរងការជំទាស់ កថាខណ្ឌ ៤៨ ("ការកែតម្រូវផ្ទះបញ្ចាំងពីឯកសារដើមនៅក្នុងប្រភពដែលបានដកស្រង់ដោយសហចៅក្រមស៊ើបអង្កេត) ។

**ខ. មូលដ្ឋានទី៥នៃបណ្តឹងឧទ្ធរណ៍៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរំលោភសិទ្ធិរបស់ជនរងគ្រោះ ដោយបានខកខានក្នុងការជូនព័ត៌មានសមស្រប និងទាន់ពេលវេលាដល់ជនរងគ្រោះក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី ដោយរំលោភវិធាន២១(១)(គ) នៃវិធានផ្ទៃក្នុង**

53. អង្គបុរេជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទិននឹងសិទ្ធិជាសារវ័ន្តរបស់ជនរងគ្រោះជាច្រើនដែលមានចែងនៅក្នុងវិធាន២១(១)(គ) នៃវិធានផ្ទៃក្នុង មានភាពគ្រប់គ្រាន់សម្រាប់ការប្តឹងឧទ្ធរណ៍លើភាពអាចទទួលយកបានស្របតាមវិធាន៧៧ *ស្ទួន*នៃវិធានផ្ទៃក្នុង[115]។ វិធាន២១(១)(គ) ចែងថា អង្គជំនុំជម្រះវិសាមញ្ញ "ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី"[116]។ វិធាននេះត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចនូវប្រយោជន៍របស់ជនរងគ្រោះ[117]។

54. ទោះបីជាសហចៅក្រមស៊ើបអង្កេតត្រូវបានចងកាតព្វកិច្ចដោយបទប្បញ្ញត្តិជាក់លាក់មួយចំនួននៅក្នុងវិធានផ្ទៃក្នុង ទាក់ទងនឹងការរក្សាការសម្ងាត់នៃការស៊ើបអង្កេត តែអង្គបុរេជំនុំជម្រះបានបញ្ជាក់ច្បាស់ថា បទប្បញ្ញត្តិជាក់លាក់ទាំងនេះ "គួរត្រូវបកស្រាយគ្រប់ពេលវេលា ដោយភ្ជាប់ជាមួយបទប្បញ្ញត្តិស្តីពីគោលការណ៍ជាសារវ័ន្តនៃដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដែលតម្រូវឱ្យ "ជូនដំណឹងដល់ជនរងគ្រោះ ព្រមទាំងគោរពដល់សិទ្ធិរបស់ជនរងគ្រោះ*នៅពេញ*ដំណើរការនីតិ

---

[115] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៥១-៥៤។

[116] វិធាន២១(១)(គ)នៃវិធានផ្ទៃក្នុង។

[117] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦១។

វិធី”[118]។ អង្គបុរេជំនុំជម្រះបានសង្កត់ធ្ងន់ថា វិធាន២១(១)(គ) នៃវិធានផ្ទៃក្នុង “មិនបានទុកចន្លោះប្រហោងសម្រាប់ការបកស្រាយនោះឡើយ ដោយវិធាននេះមិនបាននិយាយ “ឆាប់បំផុតតាមដែលអាចធ្វើទៅបាន” ឬក៏ “ក្នុងពេលណាក៏ដោយមុនពេលបញ្ចប់កិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ”[119]។

55. ការទទួលបានព័ត៌មានត្រឹមត្រូវ និងទាន់ពេលវេលានៅពេញតំណាក់កាលមុនការជំនុំជម្រះក្តី មានសារសំខាន់ជាពិសេសសម្រាប់ជនរងគ្រោះដែលអាចមានបំណងចង់ធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី។ ដោយសារជនរងគ្រោះគ្មានលទ្ធភាពចូលមើលសំណុំរឿង ពួកគេពឹងផ្អែកទាំងស្រុងលើព័ត៌មានដែលផ្សព្វផ្សាយដោយសហចៅក្រមស៊ើបអង្កេត ក្នុងការធ្វើការសម្រេចចិត្តថា តើពួកគេត្រូវដាក់ពាក្យសុំ ឬមិនដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ត្រង់ចំណុចនេះ ខណៈដែលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រូវបានដាក់នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតមិនបានផ្សព្វផ្សាយពីទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធ ដល់ជនរងគ្រោះ រហូតដល់ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ – ជិតបីឆ្នាំក្រោយ[120]។ សូម្បីតែនៅពេលនោះ សហចៅក្រមស៊ើបអង្កេតបានសម្រេចចិត្តផ្សព្វផ្សាយព័ត៌មានអំពីទីតាំងឧក្រិដ្ឋកម្ម ដើម្បីប្រឆាំងនឹងព័ត៌មានលក្ខណៈជាការ

---

[118] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៥២។

[119] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៥២។

[120] ការិយាល័យសហចៅក្រមស៊ើបអង្កេត, សេចក្តីប្រកាសព័ត៌មានចេញដោយសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ ចេញផ្សាយនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ អាចរកបាននៅលើគេហទំព័រ https://www.eccc.gov.kh/sites/default/files/media/ECCC%20PR%20OCIJ%208%20Aug%202011%20%28Eng%29.pdf។

ប៉ាន់ស្មាន និងភ័ន្តច្រឡំ ដែលធ្វើចរាចរណ៍នៅពេលដែលគ្មានសេចក្តីថ្លែងការណ៍ជាផ្លូវការរបស់សហចៅក្រមស៊ើបអង្កេតអំពីបញ្ហានេះ។ ធ្វើបែបនេះ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ជាចំហនូវ "វិមតិសង្ស័យច្បាស់លាស់" របស់ខ្លួនអំពីថា តើសំណុំរឿង ០០៤ នឹងបន្តទៅមុខដែរឬអត់ ដែលតាមរយៈនេះបង្កឲ្យមានការភ័ន្តច្រឡំ និងធ្វើឲ្យប៉ះពាល់ដល់ជំនឿរបស់ជនរងគ្រោះលើលទ្ធផលនៃការស៊ើបអង្កេត។ នៅក្នុងការផ្សព្វផ្សាយលើកដំបូងរបស់ខ្លួនអំពីទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា៖

> "ក្នុងរយៈកាលកន្លងមក ការិយាល័យសហចៅក្រមស៊ើបអង្កេត មិនបានធ្វើការជូនដំណឹងដល់សាធារណជនអំពីទីតាំងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង ០០៤ នោះទេ ដោយហេតុថា ដោយខុសពីសំណុំរឿង ០០២ សំណុំរឿង ០០៤ មានវិមតិសង្ស័យច្បាស់លាស់ថាតើជនសង្ស័យក្នុងសំណុំរឿងនេះស្ថិតនៅក្នុងប្រភេទនៃ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ស្របតាមមាត្រា ២ ស្តីពីសមត្ថកិច្ចយុត្តាធិការនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែរ ឬយ៉ាងណា។ ប្រសិនបើតុលាការមិនមានយុត្តាធិការទេ នោះវានឹងមិនមែនជារឿងសមស្របនោះឡើយក្នុងការដែលត្រូវជម្រុញឲ្យមានការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលបានចំនួន ២០០ រួចមកហើយនៅក្នុងសំណុំរឿងនេះ ព្រោះថា ការណ៍នេះអាចនឹងបង្កើតឲ្យមានការរំពឹងទុក ឬក្តីសង្ឃឹម ដែលអាចនឹងមិនសម្រេចបាននាពេលក្រោយតែប៉ុណ្ណោះ។
>
> ទោះបីជាយ៉ាងនេះក្តី ដោយយោងទៅលើហេតុដែលថា មានការកើនឡើងជាខ្លាំងនូវព័ត៌មានដែលមានលក្ខណៈជាការប៉ាន់ស្មាន និងភ័ន្តច្រឡំ ដែលបានចុះផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយនានា និងនៅលើគេហទំព័រមួយជាក់លាក់ យើងសូមធ្វើការផ្តល់ជូននូវព័ត៌មានដូចខាងក្រោម ដោយនឹងមិនធ្វើឲ្យប៉ះ

ពាល់ដល់បញ្ហាច្បាប់មួយចំនួនដែលនឹងត្រូវដោះស្រាយនៅក្នុងដីកាដំណោះស្រាយឡើយ។ [...]

នៅក្នុងដំណាក់កាលនេះនៃនីតិវិធី សហព្រះរាជអាជ្ញា មិនមានមូលដ្ឋានផ្លូវច្បាប់ក្នុងការជូនដំណឹងដល់សាធារណជនអំពីទីតាំងឧក្រិដ្ឋកម្មផ្សេងទៀតឡើយ ដូច្នេះមានតែព័ត៌មានដែលផ្តល់ដោយសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះដែលមានលក្ខណៈត្រឹមត្រូវ”[121]។

56. នៅពេញដំណាក់កាលស៊ើបអង្កេតទាំងមូល សហចៅក្រមស៊ើបអង្កេតបានរំលោភសិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលបានព័ត៌មានទាន់ពេលវេលា ដោយមិនអើពើចំពោះកម្មវត្ថុ និងគោលបំណងនៃវិធាន២១(១)(គ) នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះគួរសម្រេចថា សហចៅក្រមស៊ើបអង្កេតបានរំលោភកាតព្វកិច្ចរបស់ខ្លួននៅក្រោមវិធាន២១ ហើយសិទ្ធិជាសារវន្តរបស់ជនរងគ្រោះមិនត្រូវបានការពារបានគ្រប់គ្រាន់។

57. ជាបន្តបន្ទាប់ អង្គបុរេជំនុំជម្រះគួរពិចារណាលើការរំលោភសិទ្ធិរបស់ជនរងគ្រោះនេះ នៅពេលពិនិត្យលើការបដិសេធម្ចាស់បណ្តឹងឧទ្ធរណ៍ជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ដីកាដែលរងការជំទាស់។ ការខកខានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការផ្សព្វផ្សាយព័ត៌មានសំខាន់ៗទាន់ពេលវេលា បានធ្វើឱ្យការយឺតយ៉ាវដល់ការស៊ើបអង្កេតរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ និងមេធាវីរបស់ពួកគេ រារាំងពួក

[121] ការិយាល័យសហចៅក្រមស៊ើបអង្កេត, សេចក្តីប្រកាសព័ត៌មានចេញដោយសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ ចេញផ្សាយនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ អាចរកបាននៅលើគេហទំព័រ https://www.eccc.gov.kh/sites/default/files/media/ECCC%20PR%20OCIJ%208%20Aug%202011%20%28Eng%29.pdf។

គេក្នុងការវិភាគសមស្របលើភស្តុតាងពាក់ព័ន្ធ និងជាចុងក្រោយកម្រិតសមត្ថភាពរបស់ពួកគេក្នុងការផ្តល់ព័ត៌មានពិស្តារពាក់ព័ន្ធនឹងព្យសនកម្មពាក់ព័ន្ធ។

## VI. សេចក្តីសន្និដ្ឋាន

58. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមលើកឡើងថា ដីកាដែលរងការជំទាស់មានកំហុសលើអង្គច្បាប់ និងអង្គហេតុ ក្នុងការបដិសេធម្ចាស់បណ្តឹងឧទ្ធរណ៍សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញអត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ក។

59. ពាក់ព័ន្ធនឹងអ្វីដែលបានលើកឡើងខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមគោរពស្នើសុំអង្គបុរេជំនុំជម្រះ

(១) ជាកិច្ចការបឋម សម្រេចឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគ្រប់រូបនៅក្នុងសំណុំរឿង ០០៤/២ រួមទាំងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ ក បន្តអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលអវត្តមានសេចក្តីសម្រេចដោយមតិភាគច្រើនលើសលុបរបស់អង្គបុរេជំនុំជម្រះផ្ទុយពីនេះ ឬជំនួសសេចក្តីសម្រេចនេះ

(២) បដិសេធដីកាដែលរងការជំទាស់ដែលមានកំហុសលើអង្គច្បាប់ និងអង្គហេតុ និងពិចារណាឡើងវិញលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍នៅក្នុងឧបសម្ព័ន្ធ ក ពាក់ព័ន្ធនឹងបទដ្ឋានស្តីពីភាពអាចទទួលយកបានសមស្រប

រាប់បញ្ចូលទាំងការពិចារណាលើភាពពាក់ព័ន្ធនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថាត្រូវបានប្រព្រឹត្តនៅក្រៅភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់)។

(៣) ទទួលយកព័ត៌មានបន្ថែមដែលត្រូវបានដាក់ជូនដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

(៤) ផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ទាំងអស់ និង

(៥) ជាការជំនួស ទទួលស្គាល់ម្ចាស់ដើមបណ្តឹងដែលមិនបានទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/២ ជា “ដើមបណ្តឹង/អ្នកប្តឹង”។

សូមគោរពដាក់ជូនដោយ

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ | ជេត វណ្ណលី | ភ្នំពេញ | |
| ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ | ហុង គីមសួន | ភ្នំពេញ | |
| ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ | ឡោ ជុនធី | ភ្នំពេញ | |
| ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ | វ៉ែន ពៅ | ភ្នំពេញ | |

| | | | |
|---|---|---|---|
| ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ | សំ សុគង់ | ភ្នំពេញ | |
| ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ | ស៊ិន សុវ៉ន | ភ្នំពេញ | |
| ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ | ទី ស្រីនណា | ភ្នំពេញ | |
| ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ | Emmanuel JACOMY | ភ្នំពេញ | |
| ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ | Martine JACQUIN | ភ្នំពេញ | |
| ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ | Daniel MCLAUGHLIN | ភ្នំពេញ | |
| ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ | Lyma NGUYEN | ភ្នំពេញ | |